សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវលើអំពើនៃវត្ថុ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ផាន់ណា អានីយ៉ា**

**កញ្ញា នាង ពិសី**

សាស្ត្រាចារ្យណែនាំ

**លោក ញឹក ខុង្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ដើម្បីធ្វើគារវកិច្ចក្នុងការដឹងគុណចំពោះអ្នកមានគុណទាំងអស់ ដែលបានផ្តួចផ្តើមអោយនាងខ្ញុំមានឱកាសក្នុងការបង្ហាញនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះ ដែលជាស្នាដៃរួមរបស់នាងខ្ញុំទាំងពីរនាក់ដោយបានធ្វើការខិតខំ ប្រឹងប្រែង សិក្សាស្រាវជ្រាវ នូវសារណាមួយនេះ។ នាងខ្ញុំឈ្មោះ **ផាន់ណា អានីយ៉ា** និង **នាង ពិសី** ជានិស្សិតផ្នែកនិតីសាស្ត្រ ជំនាន់ទី២២ ឆ្នាំសិក្សា ២០១៨-២០២២ ក្រុម L4A4 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលើកយកឱកាសដ៏ថ្លៃថ្លានេះ

## សូមគោរពប្រណិប័តន៍ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

- លោកឪពុក **ផុន ផាន់ណា** និងអ្នកម្តាយ **ជិន ស៊ីនួន**
- លោកឪពុក **នាង បឿន** និងអ្នកម្តាយ **ណាន់ ស្រីឡឹប**

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងបានផ្គត់ផ្គង់រាល់តម្រូវការគ្រប់សព្វបែបយ៉ាង ព្រមទាំងអាណិតស្រលាញ់ និងបណ្តុះបណ្តាល អប់រំទូន្មានដល់រូបកូនដោយបានធ្វើការសិក្សាតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេសគឺ លោកសាស្ត្រាចារ្យ **ញឹក វុទ្ធី** ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ដោយបានពន្យល់ណែនាំ ផ្តល់នូវវិធីសាស្ត្រផ្សេងៗជាច្រើនដល់នាងខ្ញុំទាំងពីរអោយបានយល់ដឹង ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំ និងផ្តល់នូវពុទ្ធិដ៏ល្អៗ ដើម្បីទុកជាទុនដល់ការសិក្សាស្រាវជ្រាវ និងគំនិតក្នុងការបង្កើតសារណាមួយនេះ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងព្រឹទ្ធបុរសរង** ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង និងបង្កបរិយាកាសសិក្សាដ៏ល្អនៅក្នុងសាកលវិទ្យាល័យ។

លោក និង អ្នកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្រៀនអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការផ្តល់ចំនេះដឹង និងបទពិសោធន៍ជាច្រើននៅក្នុងសង្គម។

ជាកិច្ចបញ្ចប់ នាងខ្ញុំសូមធ្វើការបួងសួងដល់ទេវតាគ្រប់ព្រះអង្គ វត្ថុស័ក្តិសិទ្ធិ សូមជួយតាមថែរក្សា និងប្រោសព្រំដល់អស់លោកអ្នកមានគុណទាំងអស់អោយជួបតែសំណាងល្អ សុខភាពល្អ សេចក្តីសុខ សុភមង្គលជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាទូទៅ រាល់ទំនាក់ទំនងរបស់មនុស្សក្នុងសង្គមសព្វថ្ងៃមានការទាក់ទងគ្នាជាច្រើនទៅនឹងកិច្ចសន្យា ដែលវាជាកិរិយារបស់បុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ និងរលត់កាតព្វកិច្ចអ្វីមួយ និងព្រមទាំងមានការទទួលខុសត្រូវផងដែរ។ យ៉ាងណាមិញ ក៏មានសកម្មភាពមួយចំនួនដែលកើតឡើង ដោយគ្មានការព្រមព្រៀងគ្នាទុកជាមុនរវាងភាគីទាំងសង និងត្រូវបានគេចាត់ទុកថាជាសកម្មភាពក្រៅកិច្ចសន្យា។ ប្រសិនបើសកម្មភាពទាំងនោះបង្កឱ្យមានការខូចខាត ឬព្យសនកម្មកើតឡើង នោះច្បាប់នៅតែកំណត់ឱ្យមានការទទួលខុសត្រូវ បើទោះជាការខូចខាតនោះពុំកើតឡើងពីបុគ្គលណាមួយ ប៉ុន្តែវាអាចជាវត្ថុដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលណាមួយ។

ដោយបានឃើញពីបញ្ហាទាំងអស់នេះហើយ យើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចចិត្តធ្វើការស្រាវជ្រាវលើប្រធានបទស្តីពី "**ការទទួលខុសត្រូវលើអំពើនៃវត្ថុ**" ដើម្បីចូលរួមចំណែកក្នុងការសិក្សាអោយកាន់តែស៊ីជម្រៅចំពោះបញ្ហាខាងលើ។ ចំពោះអត្ថបទនៃកិច្ចការស្រាវជ្រាវនេះនឹងបង្ហាញជូនអំពីខ្លឹមសារសំខាន់ៗមួយចំនួន ដោយចង្អុលបង្ហាញតាមរយៈឯកសារច្បាប់ផ្សេងៗដូចជា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ អនុក្រឹត្យ និងឯកសារស្រាវជ្រាវបន្ថែមតាមរយៈប្រព័ន្ធអ៊ីនធើណែតជាដើម ដោយយើងខ្ញុំបានធ្វើការបកស្រាយពន្យល់ផ្អែកទៅលើច្បាប់ និងឯកសារពាក់ព័ន្ធដទៃទៀតយ៉ាងយកចិត្តទុកដាក់ផងដែរ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់យើងខ្ញុំទាំងពីរនាក់ ដែលកើតចេញពីការខិតខំ ប្រឹងប្រែង និងការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត រួមទាំងថវិការ ជាពិសេសរយៈពេលនៃការស្រាវជ្រាវមួយនេះ និងក្លាយទៅជាគន្លឹះមួយ ដែលជាជំនួយដល់អ្នកសិក្សាជំនាញនីតិសាស្ត្រ ជាពិសេសនិស្សិតដែលចង់ធ្វើការស្រាវជ្រាវទាក់ទងទៅនឹងការទទួលខុសត្រូវក្រៅកិច្ចសន្យា ដោយធ្វើការសិក្សាទៅលើអំពើនៃវត្ថុ។ ម្យ៉ាងទៀតយើងខ្ញុំក៏សង្ឃឹមថា អត្ថបទស្រាវជ្រាវនេះមិនមែនសម្រាប់តែនិស្សិត ដែលសិក្សាជំនាញនីតិសាស្ត្រប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាឯកសារមួយសំខាន់សម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ ព្រមទាំងសាធារណជនទូទៅនៅកម្ពុជាផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គង លើសលុប ឬខ្វះខាតទាំងឡាយដែលនឹងអាចកើតមានឡើងដោយអចេតនា ដូចជាកំហុសឆ្គងខាងអក្ខរាវិរុទ្ធ និងពាក្យពេចន៍មួយចំនួនជាដើម។ ដូច្នេះ យើងខ្ញុំរីករាយ និងស្វាគមន៍ដោយក្តីសោមនស្ស ទទួលរាល់មតិរិះគន់ ក្នុងន័យស្ថាបនាពី

សំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់ជាន់ថ្នាក់ និងពីសំណាក់មិត្តៗនិស្សិត ក៏ដូចជាគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីអភិវឌ្ឍស្នាដៃមួយនេះអោយកាន់តែល្អប្រសើរថែមទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅ**

**ផ្នែកទី១. អំពីវត្ថុ** ........ ៤

**កថាភាគទី១.និយមន័យនៃវត្ថុ** ........ ៤

**កថាភាគទី២. ប្រភេទនៃវត្ថុ** ........ ៤

១. ចលនវត្ថុ ........ ៤

១.១. ចលនវត្ថុពីកំណើត ........ ៤

១.២. ចលនវត្ថុគតិយុត្ត ........ ៥

១.៣. ចលនវត្ថុតាមកាលទិករណ៍ ........ ៥

២. អចលនវត្ថុ ........ ៥

២.១. អចលនវត្ថុពីកំណើត ........ ៥

២.២. អចលនវត្ថុពីភ័ព្វវាសនា ........ ៦

២.៣. អចលនវត្ថុតាមការកំណត់របស់ច្បាប់ ........ ៦

**ផ្នែកទី២. សញ្ញាណទូទៅនៃការទទួលខុសត្រូវ** ........ ៦

**កថាភាគទី១. លក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវ** ........ ៦

១. អំពើជាកំហុស ........ ៧

១.១. កំហុសចេតនា ........ ៧

១.២. កំហុសអចេតនា ........ ៧

២. ព្យសនកម្ម ........ ៨

២.១. ព្យសនកម្មផ្នែករូបកាយ ........ ៨

២.២. ព្យសនកម្មផ្នែកសម្ភារៈ ........ ៨

២.៣. ព្យសនកម្មផ្នែកផ្លូវចិត្ត ........ ៨

៣. ចំណងទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម ........ ៨
**កថាភាគទី២. ការទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី** ........ ៩
១. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ........ ៩
២.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ........ ១០

**ជំពូកទី ២**

**ការទទួលខុសត្រូវលើអំពើរបស់វត្ថុទូទៅ(លើកលែងសត្វ)**

**ផ្នែកទី១. ការទទួលខុសត្រូវលើសំណង់អាគារ** ........ ១១
**កថាភាគទី១. ករណីការបាក់បែក ឬដួលរលំសំណង់អាគារ** ........ ១១
១. លក្ខខណ្ឌនាំឲ្យមានការទទួលខុសត្រូវ ........ ១២
១.១. ករណីសំណង់អាគារមានវិការៈ ........ ១២
១.២. ការធ្វេសប្រហែសនៃការសាងសង់ ........ ១២
២. ការរួចផុតពីការទទួលខុសត្រូវ ........ ១៣
២.១. ករណីប្រធានសក្តិ ........ ១៣
២.២. កំហុសជនរងគ្រោះ ........ ១៣
**កថាភាគទី២. ករណីសំណង់អាគារមានអគ្គិភ័យ** ........ ១៣
១. លក្ខខណ្ឌនាំឲ្យមានការទទួលខុសត្រូវ ........ ១៤
១.១. សំណង់ដែលមានម្ចាស់គ្រប់គ្រង ........ ១៤
១.២. សំណង់ជាប្រភពនៃអគ្គិភ័យ ........ ១៤
២. ការរួចផុតពីការទទួលខុសត្រូវ ........ ១៤
២.១.សំណង់អាគារដែលមិនមែនជាប្រភពនៃអគ្គិភ័យ ........ ១៤
២.២. ករណីប្រធានសក្តិ ........ ១៤
២.៣. តតិយជន ........ ១៥
**ផ្នែកទី២. ការទទួលខុសត្រូវលើគ្រឿងសម្ភារ** ........ ១៥
**កថាភាគទី១. គ្រឿងសម្ភារ** ........ ១៥
១. និយមន័យ ........ ១៦

១.១. គ្រឿងសម្អាង ........ ១៦
១.២. អ្នកផលិតគ្រឿងសម្អាង ........ ១៦
**កថាភាគទី២. ការទទួលខុសត្រូវរបស់អ្នកផលិតគ្រឿងសម្អាង** ........ ១៦
១. ការចែកចាយគ្រឿងសម្អាងក្លែងក្លាយ ........ ១៧
២. ការចែកចាយគ្រឿងសម្អាងខូចគុណភាព ........ ១៨
**កថាភាគទី៣. ការរួចផុតពីការទទួលខុសត្រូវ** ........ ១៨
១. កំហុសអ្នកប្រើប្រាស់ ........ ១៩
២. ការយល់ព្រមពីជនរងគ្រោះ ........ ១៩
**ផ្នែកទី៣. ការទទួលខុសត្រូវលើវត្ថុមានគ្រោះថ្នាក់** ........ ២០
**កថាភាគទី១. ការទទួលខុសត្រូវលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ** ........ ២០
១. និយមន័យ ........ ២១
១.១. អាវុធ ........ ២១
១.២. គ្រឿងផ្ទុះ និងគ្រាប់រំសេវ ........ ២១
២. លក្ខខណ្ឌនៃការទទួលខុសត្រូវ ........ ២១
២.១. កំហុសក្នុងការប្រើប្រាស់ ........ ២២
២.២. កំហុសក្នុងការគ្រប់គ្រង និងថែរក្សា ........ ២២
៣. មូលហេតុនាំឲ្យរួចផុតពីការទទួលខុសត្រូវ ........ ២៣
៣.១. ការរាយការណ៍ក្នុងករណីបាត់ ........ ២៣
៣.២. ការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់ ........ ២៣
៣.៣. ករណីប្រធានសក្តិ ........ ២៤
៣.៤. កំហុសជនរងគ្រោះ ........ ២៤
៣.៥. កំហុសតតិយជន ........ ២៤
**កថាភាគទី២. ថ្នាំគីមីកសិកម្ម ( ថ្នាំ និងជីកសិកម្ម )** ........ ២៤
១. និយមន័យ ........ ២៥
២. ការទទួលខុសត្រូវ ........ ២៥

២.១. ការប្រើប្រាស់សារធាតុហាមឃាត់ ........ ២៥
២.២. ការគ្រប់គ្រង និងប្រើប្រាស់ថ្នាំកសិកម្មមិនត្រឹមត្រូវតាមបច្ចេកទេស ........ ២៦
៣. ការរួចផុតពីការទទួលខុសត្រូវ ........ ២៧
៣.១. កំហុសអ្នកប្រើប្រាស់ ........ ២៧
៣.២. ករណីប្រធានសក្តិ ........ ២៧
**ផ្នែកទី៤. វត្ថុទូទៅផ្សេងៗ** ........ **២៧**
**កថាភាគទី១. ការទទួលខុសត្រូវលើវត្ថុទូទៅផ្សេងៗ** ........ **២៧**
១. វត្ថុមាននៃវត្ថុ ........ ២៨
២. បុគ្គលដែលមានកាតព្វកិច្ចថែរក្សាវត្ថុ ........ ២៨
៣. ការចូលរួមរបស់របស់វត្ថុ ........ ២៩
**កថាភាគទី២. មូលហេតុនាំឲ្យរួចផុតពីការទទួលខុសត្រូវ** ........ **២៩**
១. ករណីប្រធានសក្តិ ........ ៣០
២. តតិយជន ........ ៣០
៣. កំហុសជនរងគ្រោះ ........ ៣០

**ជំពូកទី ៣**

**ការទទួលខុសត្រូវលើអំពើរបស់សត្វ**

**ផ្នែកទី១. អំពីសត្វ និងអ្នកកាន់កាប់សត្វ** ........ **៣១**
**កថាភាគទី១. ប្រភេទនៃសត្វ និងការទទួលខុសត្រូវ** ........ **៣១**
១. សត្វព្រៃ ........ ៣១
២. សត្វស្រុក ........ ៣២
**កថាភាគទី២. អំពីអ្នកកាន់កាប់សត្វ** ........ **៣២**
១. និយមន័យ ........ ៣២
២. លក្ខណៈសម្បត្តិរបស់អ្នកកាន់កាប់សត្វ ........ ៣២
២.១. អ្នកកាន់កាប់សត្វជាកម្មសិទ្ធករ ........ ៣៣
២.២. អ្នកកាន់កាប់សត្វមិនជាជាកម្មសិទ្ធករ ........ ៣៣

**ផ្នែកទី២. ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ ........................................ ៣៤**
**កថាភាគទី១. លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ ........ ៣៤**
១. ការចូលរួមសកម្មពីសត្វ ........................................................................................ ៣៤
២. ទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម ......................................................................... ៣៥
**កថាភាគទី២. ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ........ ៣៥**
១. ករណីប្រធានសក្តិ.................................................................................................. ៣៦
២. តតិយជន........................................................................................................... ៣៦
៣. កំហុសជនរងគ្រោះ................................................................................................. ៣៦
**សេចក្តីសន្និដ្ឋាន ............................................................................................. ៣៧**
**អនុសាសន៍ ..................................................................................................... ៣៩**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បណ្តាប្រទេសទូទាំងសកលលោក សុទ្ធតែមានច្បាប់ដែលបានបង្កើតឡើងស្របទៅតាមបរិបទនៃប្រទេសនិមួយៗ ដោយអាស្រ័យទៅតាមប្រពៃណី ទំនៀមទំលាប់ សាសនា ក៏ដូចជាទីតាំងភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ ដើម្បីធ្វើការគ្រប់គ្រងទៅលើស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម។ ជាក់ស្តែង ចំពោះប្រទេសកម្ពុជាយើង ក៏មានការបង្កើតនូវច្បាប់ជាច្រើន ហើយច្បាប់មួយចំនួនត្រូវបាននិរាករណ៍ ឬត្រូវបានធ្វើវិសោធនកម្ម ទៅតាមបរិបទនៃសង្គមក្នុងគោលបំណងផ្តល់បង្កើនភាពងាយស្រួលក្នុងការគ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិ។ រីឯការអនុវត្តច្បាប់នៅកម្ពុជាយើងគឺកាន់តែល្អប្រសើរឡើង ដោយការប្រកាន់ភ្ជាប់នូវនីតិរដ្ឋ។

ជាក់ស្តែង ការបង្កើតច្បាប់ទាក់ទងទៅនិងផ្នែករដ្ឋប្បវេណី ក្នុងនោះមានកំណត់អំពីការប្រាស្រ័យទាក់ទងគ្នាទាំងអស់ក្នុងសង្គមសព្វថ្ងៃ ដែលសុទ្ធសឹងតែកើតចេញពីឆន្ទៈដែលបានត្រូវរ៉ូវ ឬស្រុះស្រួលគ្នារវាងបុគ្គល និងបុគ្គល និងបង្កើតបានជាកិច្ចសន្យាដែលមានអានុភាពចងជាកាតព្វកិច្ច រួមទាំងមានការទទួលខុសត្រូវផងដែរ។ ទៀតសោត ក្នុងករណីខ្លះទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ពុំមានការកើតឡើងដោយទំនាក់ទំនងគតិយុត្តជាមុនឡើយ ដោយក្នុងច្បាប់បានបញ្ញត្តិថាជាអំពើអនីត្យានុកូល ហើយត្រូវមានការទទួលខុសត្រូវក្រៅកិច្ចសន្យាលើការខូតខាតដែលមិនត្រឹមតែចំពោះកំហុសផ្ទាល់ខ្លួនរបស់ចារីនៃអំពើតែប៉ុណ្ណោះទេ ថែមទាំងត្រូវទទួលខុសត្រូវទៅលើវត្ថុដែលជាកម្មសិទ្ធរបស់ខ្លួនផងដែរ។ យ៉ាងណាក៏ដោយ ក៏មានករណីមួយចំនួនដែលអាចនាំឲ្យមានការរួចផុតពីការទទួលខុសត្រូវ។

ទំនាស់ក្រៅកិច្ចសន្យា ត្រូវបានសង្កេតឃើញថាបានកើតឡើងច្រើនក្នុងការរស់នៅប្រចាំថ្ងៃ។ ចំណែកឯការដោះស្រាយទំនាស់គឺមានភាពស្មុគស្មាញ ដោយខ្វះនូវភាពយល់ដឹងខាងផ្នែកច្បាប់រវាងភាគី និងភាគី បង្កឲ្យកើតមានជម្លោះ ឈានទៅដល់ការប្តឹងតវ៉ាគ្នាទៅវិញទៅមក។ បុគ្គលទូទៅមួយចំនួន នៅមានភាពស្រពិចស្រពិលក្នុងការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសរដ្ឋប្បវេណី។ ហេតុនេះហើយ នៅពេលមានវិវាទកើតឡើង ពួកគេតែងតែចាត់ទុកថាជារឿងព្រហ្មទណ្ឌ ដោយស្មានទម្ងន់ទោសនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរជាងស្មានទម្ងន់ទោសនៃការទទួលខុសត្រូវខាងរដ្ឋប្បវេណី ក៏ដូចជាកម្លាចភាគីម្ខាងទៀតឲ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែ វាក៏មិនមែនមានន័យថាវិវាទរឿងរដ្ឋប្បវេណីពុំមានមូលហេតុពីបទ

ល្មើសព្រហ្មទណ្ឌដែរ។ មានន័យថា ការធ្វើបណ្ដឹងក្នុងការទទួលខុសត្រូវរដ្ឋប្បវេណីអាចក្នុងករណីជាមូលហេតុព្រហ្មទណ្ឌ ឬ មូលហេតុរដ្ឋប្បវេណី ឬ មូលហេតុទាំងពីរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សានេះ និងបង្ហាញអំពីលក្ខខណ្ឌទាំងឡាយដែលនាំឲ្យកើតមានកាតព្វកិច្ចទទួលខុសត្រូវ ឬមិនទទួលខុសត្រូវលើអំពើនៃវត្ថុ បូករួមនិងការស្វែងរកនីតិវិធីដោះស្រាយវិវាទឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយបញ្ហាវិវាទក្រៅកិច្ចសន្យាតាមរយៈការបង្កើនការយល់ដឹងដែលមានចំណុចដូចជា៖

១. តើវត្ថុអ្វីខ្លះដែលអាចបង្កើតឲ្យមានព្យសនកម្មដល់ជនរងគ្រោះ?

២. តើលក្ខខណ្ឌណាខ្លះដែលមានអានុភាពចងកាតព្វកិច្ច ឬពុំអាចចងកាតព្វកិច្ចកម្មសិទ្ធករនៃវត្ថុឲ្យធ្វើការទទួលខុសត្រូវ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសិក្សាស្វែងយល់អំពីមូលហេតុដែលនាំឲ្យមានការទទួលខុសត្រូវលើអំពើអនីត្យានុកូល ក្នុងករណីវត្ថុរបស់កម្មសិទ្ធិករបង្កឲ្យមានព្យសនកម្មដល់ភាគីរងគ្រោះ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវមួយនេះមានបំណងចង់បង្ហាញអំពីមូលហេតុដែលនាំឲ្យរួចផុតពីការទទួលខុសត្រូវផងដែរ។ ទន្ទឹមនឹងនេះ ជាការចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិដោយចែករំលែកនូវពុទ្ធិដល់មិត្តៗនិស្សិតអ្នកអាន ក៏ដូចជាសាធារណជនទូទៅ សម្រាប់ជាស្មារតីមួយចំណែកក្នុងការបង្កើនការយល់ដឹងនៃការដោះស្រាយវិវាទក្រៅកិច្ចសន្យា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំនាក់ទំនងសង្គមក្នុងជីវភាពប្រចាំថ្ងៃ ស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ និងត្រូវបានចាត់ចូលជាអំពើគតិយុត្ត កាលណាវាបង្កើតឲ្យមានអានុភាពខាងផ្លូវច្បាប់ បើទោះបីជាវាស្ថិតនៅក្រៅឆន្ទៈរបស់បុគ្គល ក៏ច្បាប់នៅតែកំណត់ឲ្យជាប់កាតព្វកិច្ច។ តួយ៉ាង អត្ថបទស្រាវជ្រាវក្រោមប្រធានបទ "**ការទទួលខុសត្រូវលើអំពើនៃវត្ថុ**" មួយនេះមានទំហំនៃការស្រាវជ្រាវ ដែលផ្ដោតទៅលើគោលការណ៍ទូទៅនៃការទទួលខុសត្រូវរបស់កម្មសិទ្ធករ ចំពោះវត្ថុ ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន រួមជាមួយនឹងមូលហេតុនាំឲ្យរួចផុតពីកាតព្វកិច្ចនេះផងដែរ។

មួយវិញទៀត ដែនកំណត់នៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើសកម្មភាព ឬអំពើខាងសម្ភារៈមិនចំណុះឲ្យឆន្ទៈបុគ្គល ហើយជារឿយៗត្រូវបានកត់សម្គាល់ថាបានបង្កជាវិវាទក្នុងករណីមួយចំនួនដែលកំណត់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ននេះ ដោយមានក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ជាសំអាង និងមិនផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដោយប្រធានបទស្តីពី "ការទទួលខុសត្រូវលើអំពើនៃវត្ថុ" មានបំណងឲ្យអ្នកអានបានយល់ដឹងនូវគោការណ៍នៃការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ដើម្បីជាទុនមួយក្នុងការយល់ដឹងដ៏មានសារៈសំខាន់សម្រាប់ជាប្រយោជន៍ដល់ការស្វែងយល់នូវចំណុចមូលដ្ឋានសំខាន់ៗ នៃការទទួលខុសត្រូវលើការខូចខាតដែលកើតចេញពីវត្ថុ ។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះគឺបានរួមចំណែកលើកស្ទួយភាសាជាតិ ដោយបង្កើនឯកសារស្រាវជ្រាវជាភាសារខ្មែរ រួមទាំងបង្កើនឯកសារនៃអំពើរដ្ឋប្បវេណីដែលជាកាតព្វកិច្ចអនីត្យានុកូលនិងការទទួលខុសត្រូវបន្ថែមទៀត ដើម្បីផ្តល់ភាពងាយស្រួលក្នុងការស្វែងយល់ និងមានភាពងាយស្រួលរកផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

តាមរយៈការសិក្សា ការអាន ការស្រាវជ្រាវ និងការស្វែងយល់ ដើម្បីទទួលបានឯកសារផ្សេងៗដែលទាក់ទងទៅនិងគោលការណ៍ទូទៅនៃការទទួលខុសត្រូវលើអំពើនៃវត្ថុ សម្រាប់ជាជំនួយស្មារតីដល់មិត្តអ្នកអាននិក្ខេបបទនេះចែកចេញជា ៣ ជំពូក ដើម្បីយល់កាន់តែច្បាស់ និងស៊ីជម្រៅទៅលើចំណោទបញ្ហាដែលបានលើកឡើងទាក់ទងទៅនិងប្រធានបទទាំងមូល មានជាអាទិ៍៖

ជំពូក១. សញ្ញាណទូទៅ

ជំពូក២. ការទទួលខុសត្រូវលើអំពើរបស់វត្ថុទូទៅ(លើកលែងសត្វ)

ជំពូកទី៣. ការទទួលខុសត្រូវលើអំពើរបស់សត្វ

# ជំពូកទី១

# សញ្ញាណទូទៅ

# ជំពូកទី១

# សញ្ញាណទូទៅ

## ផ្នែកទី១. អំពីវត្ថុ

### កថាភាគទី១. និយមន័យនៃវត្ថុ

សម្ភារៈ ឧបករណ៍ប្រើប្រាស់ និងរបស់របរផ្សេងៗដែលនៅជុំវិញខ្លួនយើងគឺជាវត្ថុ ដោយនៅក្នុងច្បាប់បានបញ្ញត្តិសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង[1]។ ជាឧទាហរណ៍ទៅលើរបស់ទាំងអស់នោះមានដូចជា ដុំឥដ្ឋជាសារធាតុរឹង ទឹកភេសជ្ជៈជាសារធាតុរាវ និងអុកស៊ីហ្សែនជាវត្ថុដែលមានសារធាតុឧស្ម័ន។ យោងតាមនិយមន័យខាងលើ យើងអាចកំណត់បានម្យ៉ាងទៀតថាវត្ថុអាចជារបស់មានវិញ្ញាណ និងរបស់គ្មានវិញ្ញាណ។ វត្ថុគ្មានវិញ្ញាណ មានដូចជាសៀវភៅ សំណង់អគារ និងអាវុធជាដើម។ ចំណែកឯវត្ថុមានវិញ្ញាណវិញ គឺសំដៅលើសត្វ។ ដោយឡែក នៅក្នុងច្បាប់បាននូវប្រភេទនៃវត្ថុផងដែរ។

### កថាភាគទី២. ប្រភេទនៃវត្ថុ

ក្នុងក្រមរដ្ឋប្បវេណី បានបែងចែកវត្ថុជាពីរប្រភេទដាច់ដោយឡែកពីគ្នារួមមានចលនវត្ថុ និងអចលនវត្ថុ។ នៅក្នុងប្រភេទនីមួយៗ ក៏ត្រូវបានបែងចែកជាប្រភេទផ្សេងៗផងដែរ។

#### ១. ចលនវត្ថុ

ចលនវត្ថុ គឺសំដៅទៅលើវត្ថុដែលអាចផ្លាស់ទីបាន ឬអាចដកចេញបានដោយមិនធ្វើឲ្យខូចទ្រង់ទ្រាយដើមរបស់វត្ថុអ្វីមួយ ហើយវាមិនត្រូវបានចាត់ទុកជាប្រភេទនៃអចលនវត្ថុនោះទេ[2]។ មានន័យថា វាសំដៅទៅលើវត្ថុដែលអាចរំកិល ឬ ផ្លាស់ទីតាំងបានដោយកម្លាំងខាងក្រៅ ដែលមានដូចជារបស់របរផ្ទាល់ខ្លួន ឬ ទ្រព្យសម្បត្តិទាំងឡាយដែលមិនមែននៅមួយកន្លែងជាអចិន្ត្រៃយ៍។ ឧទាហរណ៍ កង្ហារ គ្រែ កៅអី ទោចក្រយានយន្ត ត្រីចក្រយានយន្តជាដើម។ ប្រភេទនៃអចនលវត្ថុ ត្រូវបានបែងចែកជាបីមានដូចជា ចលនវត្ថុពីកំណើត ចលនវត្ថុគតិយុត្ត និងចលនវត្ថុតាមកាលទិករណ៍[3]។

##### ១.១. ចលនវត្ថុពីកំណើត

[1] មាត្រា១៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[2] មាត្រា១២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[3] ហាប់ ផល្លី, កែសម្រួល, នីតិរដ្ឋប្បវេណី១ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១៥), ៣២-៣៣។

ចលនវត្ថុពីកំណើត គឺជាទ្រព្យមើលឃើញផ្ទាល់ភ្នែក (រូបិយ) ហើយអាចផ្លាស់ប្តូរទីកន្លែងបានដោយខ្លួនឯង ឬត្រូវទទួលកម្លាំងចលករពីខាងក្រៅជួយ មានដូចជា ម៉ូតូ កង់ ទូ សត្វពាហនៈ។

**១.២. ចលនវត្ថុគតិយុត្ត**

ចលនវត្ថុគតិយុត្តឬ ជាចលនវត្ថុតាមច្បាប់កំណត់ គឺជាការកំណត់ដោយច្បាប់ទៅអោយរូបវន្តបុគ្គលឬនិតិបុគ្គលទទួលបានសិទ្ធពេញលេញ ឬការពារតាមផ្លូវច្បាប់។ ជាក់ស្តែង ចំពោះវត្ថុដែលគ្មានរូបរាង ហើយអាចប្រើគ្រប់គ្រងបាន ក៏ត្រូវបានចាត់ជាចលនវត្ថុផងដែរមានដូចជាចរន្តអគ្គីសនី ឧស្ម័នហ្គាសជាដើម[4]។

**១.៣. ចលនវត្ថុតាមកាលទិករណ៍**

ចលនវត្ថុតាមកាលទិករណ៍ ជាវត្ថុកើតពីធម្មជាតិ ឬមនុស្សអ្នកដាំហើយឲ្យផងតាមកាលវេលាកំណត់នាពេលខាងមុខមានដូចជាដំណាំស្រូវ ស្វាយ ចេក បន្លែ។

ដោយហេតុថា ចលនវត្ថុជាប្រភេទនៃវត្ថុដែលអាចធ្វើការបំលាស់ទីបានបែបនេះ ទើបវាត្រូវបានចាត់ទុកថាជាវត្ថុសកម្ម ដែលអាចមានចលនា ឬអំពើប៉ះទង្គិចទៅលើភាគី ឬជនរងគ្រោះណាមួយបណ្តាលឲ្យមានការខូចខាតកើតឡើង។ ឧទាហរណ៍ : ឡានចតនៅលើទីទួល ដោយខ្វះការប្រុងប្រយត្ន័ក៏បានរអិលថយក្រោយទៅកិនមនុស្ស ជាហេតុធ្វើឲ្យមានព្យសនៈកម្មកើតឡើង។

**២. អចលនវត្ថុ**

អនុលោមតាមមាត្រា១២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អចលនវត្ថុ ត្រូវបានគេកំណត់ថាជាដីធ្លី និងវត្ថុជាប់នៅលើដីហើយមិនអាចផ្លាស់ទីបានមានដូចជា អាគារ សំណង់ផ្សេងៗ ដំណាំ រុក្ខជាតិ ជាអាទិ៍។ ប៉ុន្តែ គួរបញ្ជាក់ផងដែរថា នៅពេលនេះយើងមិនបានធ្វើការសិក្សាលើដីធ្លីឡើយ។ ដោយឡែក ច្បាប់បានបញ្ញត្តិនូវអចលនវត្ថុមាន៣ប្រភេទមានដូចជាអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងតាមការកំណត់របស់ច្បាប់[5]។

**២.១. អចលនវត្ថុពីកំណើត**

[4] មាត្រា១២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[5] មើលមាត្រា២ ច្បាប់ភូមិបាល ឆ្នាំ២០០១។

អចលនវត្ថុពីកំណើត ជាអចលនវត្ថុកើតពីធម្មជាតិ ឬអំពើរបស់មនុស្ស ហើយវាមិនអាចបំផ្លាស់ប្តូរទីតាំង ឬរំកិល ព្រោះនាំឲ្យខូចខាតរូបរាង ឬតំលៃរបស់វា មានជាអាទិ៍ ៖ ដី ព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ដីមិនអាចដាំដុះ ដីលិចទឹក ដីសំណង់ ដីរៀបចំផ្សេងទៀត។

### ២.២. អចលនវត្ថុពីភ័ព្វវាសនា

អចលនវត្ថុពីភ័ព្វវាសនា គឺជាផលដែលកើតចេញ ពីអលនទ្រព្យ មានដូចជាដើមឈើ ដំណាំហូបផ្លែ ដែលមិនទាន់ប្រមូលផលព្រោះវានៅជាប់នឹងដើមនៅឡើយ[6]។

### ២.៣. អចលនវត្ថុតាមការកំណត់របស់ច្បាប់

អចលនវត្ថុតាមការកំណត់របស់ច្បាប់ គឺជាសិទ្ធិប្រត្យក្ស ឬហៅសិទ្ធិភណ្ឌិក ជាសិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុដែលអាចអះអាងចំពោះជនដទៃបាន មានជាសិទ្ធិភណ្ឌិក ឬសិទ្ធិជាម្ចាស់ទ្រព្យលើអចលនទ្រព្យ។

ផ្អែកលើនិយមន័យខាងលើ យើងអាចនិយាយបានថានេះជាវត្ថុអកម្ម ដោយហេតុថាវាជាវត្ថុស្ថិតនៅនឹងមួយកន្លែង ហើយគ្មានអំពើប៉ះទង្គិចលើភាគីណាមួយដោយបង្កឲ្យមានការខូចខាតកើតឡើងទេ។ ប៉ុន្តែ បើសិនណាវាត្រូវបានទុកដាក់មិនត្រូវ នោះវត្ថុអកម្មនឹងក្លាយទៅជាវត្ថុអកម្មខុសច្បាប់ ដោយបង្កឱ្យមានការខូចខាតកើតឡើង[7]។

ឧបមាថា រថយន្តមួយដែលខូចហើយបានចតចោលនៅផ្លូវនៅពេលយប់ងងឹត ហើយមិនបានដាក់ភ្លើងភ្លើងសញ្ញា រឺ មែកឈើដើម្បីបង្ហាញទេ បើសិនណាជាមានបុគ្គលណាម្នាក់បានជិះទៅបុករថយន្តនោះហើយមានរបួសជាទម្ងន់ ក្នុងករណីនេះ ម្ចាស់ ឬកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងរថយន្ត ត្រូវទទួលខុសត្រូវទៅតាមផ្លូវច្បាប់។

## ផ្នែកទី២. សញ្ញាណទូទៅនៃការទទួលខុសត្រូវ

## កថាភាគទី១. លក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវ

ការទទួលខុសត្រូវ គឺជាកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗដែលត្រូវធានារ៉ាប់រងអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ដោយទទួលយកផលវិបាកនៃអំពើទាំងនោះ។ ក្នុងន័យនេះដែរ ការទទួលខុសត្រូវអាចកើតឡើងបាន លុះត្រាតែមានអំពើដែលបង្កឲ្យមានការខូចខាតដល់ភាគីណាមួយ។

---

[6] ហាប់ ផល្លី, កែសម្រួល, នីតិរដ្ឋប្បវេណី១ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១៥), ៣៣។

[7] ញឹក វុធ្វី, នីតិកាតព្វកិច្ច២ (២០២១)។

ហេតុនេះ លក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវ មាន៣គឺ អំពើជាកំហុស ព្យសនៈកម្ម និងចំណងទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម។

## ១. អំពើជាកំហុស

កំហុស គឺជាលក្ខខណ្ឌមួយនៃការទទួលខុសត្រូវ ហើយដើម្បីឲ្យមានការទទួលខុសត្រូវចំពោះព្យសនកម្មទៅបាន លុះត្រាតែអំពើនោះជាកំហុសបានបង្កឡើងនូវព្យសនកម្មដល់ភាគីរងគ្រោះ។

កំហុស គឺជាសកម្មភាពដោយផ្ទុយនឹងច្បាប់ដែលបុគ្គលណាមួយបានប្រព្រឹត្ត ដោយបំពានទាក់ទងទៅនឹងសិទ្ធ ឬផលប្រយោជន៍របស់អ្នកដទៃដោយចេតនាក្តី ឬដោយអចេតនាក្តី ហើយចារីនៃអំពើត្រូវទទួលខុសត្រូវសងការខូចខាត ដែលបានកើតឡើងដោយអំពើនោះ[8]។ មានន័យថា គឺជាឆន្ទៈរបស់បុគ្គលណាមួយដែលបានប្រព្រឹត្តនូវអំពើនាំឲ្យមានព្យសនកម្មកើតឡើងដល់អ្នកដទៃ ហើយអំពើជាកំហុសនោះអាចកើតឡើងក្រោមរូបភាពចេតនា ឬអចេតនា។

ដូចនេះ កំហុសត្រូវបានបែងចែកជាពីរគឺ កំហុសចេតនា និងកំហុសអចេតនា។

### ១.១. កំហុសចេតនា

កំហុសចេតនា ជាអំពើបំពានដោយព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ[9]។ ចារីនៃអំពើមានឆន្ទៈខាងផ្លូវចិត្ត ក្នុងការប្រព្រឹត្តអំពើ ឬធ្វើសកម្មភាពបង្កការខូចខាតណាមួយដោយបានដឹងច្បាស់ពីជាមុនចំពោះផលវិបាកនៃការទទួលខុសត្រូវ ប៉ុន្តែនៅតែមិនព្រមបញ្ឈប់ទង្វើរបស់ខ្លួន។

### ១.២. កំហុសអចេតនា

កំហុសអចេតនា ជាអំពើដែលកើតឡើងពីភាពធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ខ្ជីខ្ជារបស់ចារីនៃការខូចខាត ដោយមិនពុំបានធ្វើការគិតទុកជាមុន ឬមិនអាចព្យាករណ៍ទុកមុនថាការប្រព្រឹត្តសកម្មភាពរបស់ខ្លួនបានបង្កភាពអន្តរាយដល់ជនណាមួយឡើយ[10]។ ចំពោះកំហុសនេះ មិនបានគិតទៅលើឆន្ទៈខាងផ្លូវចិត្តរបស់សាមីខ្លួនអ្នកប្រព្រឹត្តអំពើនោះទេ[11]។

[8] មាត្រា៧៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[9] មាត្រា៧៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[10] មាត្រា៧៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[11] មាត្រា៧៤២ សេចក្តីកំណត់ចំពោះមាត្រានីមួយៗឆ្នាំ២០១០នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ២. ព្យសនកម្ម

ព្យសនៈកម្ម មានន័យថាជាការខូចខាត ឬសេចក្តីវិនាសអន្តរាយដែលប៉ះពាល់ដល់ខាងសម្ភារៈ រូបកាយ និងផ្លូវចិត្ត ដោយបណ្តាលមកពីអំពើជាកំហុសរបស់អ្នកដ៏ទៃ។

ដូចក្នុងករណី អ្នកលក់ថ្នាំលេបសម្រករាងម្នាក់ ទោះដឹងថាថ្នាំលេបសម្រករាងនោះមានសារធាតុគីមីខ្លាំងក៏ដោយ ក៏នៅតែយកវាមកលក់ឲ្យអតិថិជន ដើម្បីផលប្រយោជន៏អាជីវកម្មរបស់ខ្លួនដែលវាបណ្តាលឲ្យមានការខូចខាតដល់អ្នកប្រើប្រាស់យ៉ាងធ្ងន់ធ្ងរ ដោយប៉ះពាល់ដល់សរីរាង្គខាងក្នុង ថែមទាំងបង្កជម្ងឺផ្សេងៗ។

ព្យសនកម្មរួមមានបីប្រភេទដូចជា ព្យសនកម្មផ្នែករូបកាយ ព្យសនកម្មផ្នែកសម្ភារៈ និងព្យសនកម្មផ្នែកផ្លូវចិត្ត។

### ២.១. ព្យសនកម្ម ផ្នែករូបកាយ

ព្យសនកម្មផ្នែករូបកាយ គឺជាការខូចខាតទាំងឡាយណាដែលប៉ះពាល់ដល់រូបរាងកាយជនរងគ្រោះ ឬដល់អាយុជីវិតរបស់ជនរងគ្រោះ ដែលបណ្តាលមកពីអំពើល្មើសណាមួយ ដែលចារីបានបង្ក។ ការខូចខាតនោះអាចបង្កឲ្យមានរបួសស្នាម ពិការភាព ខូចសម្ផស្ស ជាដើម។

### ២.២. ព្យសនកម្ម ផ្នែកសម្ភារៈ

ព្យសនកម្មផ្នែកសម្ភារៈ គឺជាការខូតខាតទាំងឡាយណាដែលទាក់ទងទៅនឹងវត្ថុ ឬទ្រព្យសម្បត្តិរបស់ជនរងគ្រោះមានដូចជា ការបាត់បង់ ការខូចខាតទៅលើសម្ភារៈប្រើប្រាស់ ឬការមិនទទួលបាននូវផលចំណេញជាដើម។

### ២.៣. ព្យសនកម្ម ផ្នែកផ្លូវចិត្ត

ព្យសនកម្មផ្នែកផ្លូវចិត្ត គឺជាការខូចខាតដែលគេមិនអាចមើលឃើញ មានដូចជាការប៉ះពាល់ដល់កិតិយស កេរ្តិ៍ឈ្មោះ និងផ្លូវអារម្មណ៍ ប៉ុន្តែគេតម្រូវឲ្យមានការសងការខូចខាតនោះ។

## ៣. ចំណងទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម

ចំណងទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម គឺជាទំនាក់ទំនងរវាងអំពើដែលជាកំហុសជាមួយនឹងការខូចខាតមានន័យថាព្យសនកម្មបានកើតឡើងភ្លាមៗ ឬបន្ទាប់ពីអំពើប្រព្រឹត្តបានកើតឡើង ឬក៏អាចនិយាយម្យ៉ាងទៀតថា ទំនាក់ទំនងហេតុនិងផលនៃការកើតឡើងនៃការខូចខាតចំពោះជនរងគ្រោះ និងកំហុសរបស់ចារី។ វាជារឿងចាំបាច់ដែលត្រូវកំណត់ទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម ដើម្បីកំណត់ថាចារីបានបង្កឲ្យមានការ

ខូចខាតដល់ជនរងគ្រោះ។ ក្នុងការបង្ហាញឲ្យឃើញនូវអត្ថិភាពនៃទំនាក់ទំនងមួយយ៉ាងពិតប្រាកដ អំពីទំនាក់ទំនងអំពើដែលបានប្រព្រឹត្តជាមួយនិងព្យសនកម្ម ជាបន្ទុករបស់ជនរងគ្រោះជាអ្នកបញ្ជាក់បង្ហាញថា ចំណងហេតុផលគឺពិតប្រាកដហើយត្រូវតែជាអំពើរបស់ចារីផ្ទាល់[12]។ ដូចមានចែងក្នុងកថាខណ្ឌទី៣ មាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំពោះកំហុសចេតនាឬកំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុនិងផលរវាងអំពើរបស់អ្នកប្រព្រឹត្តិអំពើបំពាន និងការកើតឡើងនៃការខូចខាតនិងការខូចខាតដែលកើតឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះត្រូវបញ្ជាក់បង្ហាញ។

ដូចករណីថា ភាគី ក ជាម្ចាស់ភោជនីយដ្ឋាន បានលក់ចំណីអាហាររបស់របស់ខ្លួនទៅភាគី ខ ដែលជាអ្នកទិញ។ ក្រោយពីបានទិញចំណីពីភាគី ក យកទៅបរិភោគរួចមកនោះភាគី ខ ស្រាប់តែមានការរាគរូសខ្លាំង។

ក្នុងករណីនេះ ចំណងហេតុផល គឺស្ថិតនៅត្រង់ការរាគរូសរបស់ភាគី ខ បណ្តាលមកពីការបរិភោគចំណីគ្មានគុណភាព ឬគ្មានអនាម័យល្អ មិនមែនការរាគរូសរបស់ភាគី ខ បណ្តាលមកពីការឈឺអ្វីផ្សេងនោះទេ។ ដូច្នេះទំនាក់ទំនងហេតុនិងផលត្រូវតែទាក់ទងគ្នាទើបអាចមានព្យសនកម្មបាន។

## កថាភាគទី២. ការទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី

ការទទួលខុសត្រូវលើអនីត្យានុកូល អាចកើតឡើងលុះត្រាតែមានការខូចខាត ។ ការខូចខាតនោះវាអាចកើតចេញពីបទល្មើសរដ្ឋប្បវេណី ឬខ្លះទៀតវាអាចទាក់ទងទៅនិងមូលហេតុព្រហ្មទណ្ឌ។ ហេតុនេះ ក្នុងរឿងរដ្ឋប្បវេណី អាចមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

### ១. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីត្រង់កថាខណ្ឌទី ១ បានកំណត់ថា បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬ ដោយអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។ ហេតុនេះ ការទទួលខុសត្រូវ ផ្នែករដ្ឋប្បវេណី ជាទណ្ឌកម្មមួយដែលមានគោលបំណងធានានូវការសងសំណងខូចខាតចំពោះជនរងគ្រោះ មានដូចជាសំណងជាប្រាក់ ការហាមមិនឱ្យធ្វើសកម្មភាពណាមួយ ការស្តារឡើងវិញនូវស្ថានភាពដើម និងការប្រគល់ត្រលប់វិញ និងការសុំអភ័យទោសជាសាធារណៈ។ ដោយឡែក ជាទូទៅយើងសង្កេតឃើញថាការសងសំណងលើការខូចខាតភាគច្រើនត្រូវបានទូទាត់ជាសាច់ប្រាក់សម្រាប់ជនរងគ្រោះផ្ទាល់ ព្រោះវាមានភាពងាយស្រួលក្នុងការគណនា ហើយវាក៏

[12] ញឹក វុធ្និ, នីតិកាតព្វកិច្ច២ (២០២១)។

ត្រូវបានកំណត់ជាគោលការណ៍ក្នុងច្បាប់[13]។ ការគណនាចំនួនទឹកប្រាក់នៃការខូចខាត គឺត្រូវ បានវិនិច្ឆ័យទៅលើស្ថានភាពជាក់ស្តែងនៃអំពើនិងទំហំភាពអន្តរាយដែលបានកើតឡើង[14]។

មួយវិញទៀត អាជ្ញាយុកាលនៃការរំលត់ សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណង ការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង[15]។

## ២.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

ក្នុងរឿងរដ្ឋប្បវេណី អាចមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ កាលណាមានព្យសនកម្មជាមូលហេតុបង្កឲ្យមានបទល្មើសព្រហ្មទណ្ឌ។ ការទទួលខុសត្រូវ នេះមានគោលបំណងក្នុងការដាក់ទោសចំពោះអ្នកប្រព្រឹត្តអំពើល្មើសច្បាប់ ឱ្យមានការរាងចាល មិនហ៊ានល្មើសច្បាប់ទៀតនៅថ្ងៃខាងមុខ តាមរយៈទោសដាក់ពន្ធនាគារ ព្រមទាំងទោសពិន័យជាប្រាក់។ ចំពោះទោសពិន័យជាប្រាក់ យើងអាចនិយាយបានថាជាទោសដែលមានកម្រិតស្រាល ពោលជនបង្កបានប្រព្រឹត្តឲ្យមានការខូចខាតមិនធ្ងន់ធ្ងរ។ វាផ្ទុយពីទោសដាក់ពន្ធនាគារ ដែលអ្នកបង្កបានប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរខ្លាំង និងមិនអាចលើកលែងបានដោយបានកំណត់ចែងក្នុងច្បាប់ យ៉ាងច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌ។

[13] មាត្រា៧៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[14] មើលមាត្រា៧៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[15] មាត្រា៧៦៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី២

# ការទទួលខុសត្រូវលើអំពើរបស់វត្ថុទូទៅ

# ( លើកលែងសត្វ )

# ជំពូកទី២

# ការទទួលខុសត្រូវលើអំពើរបស់វត្ថុទូទៅ(លើកលែងសត្វ)

យើងនឹងធ្វើការសិក្សាទៅលើផ្នែកចំនួន៤ ដោយចំណុចទាំងអស់នោះសមស្របទៅនិងបរិបទសង្គមជាក់ស្តែងមានដូចជាការទទួលខុសត្រូវលើសំណង់អាគារ គ្រឿងសម្ភាង និងវត្ថុមានគ្រោះថ្នាក់ ក៏ដូចជាការទទួលខុសត្រូវលើវត្ថុផ្សេងៗ។

## ផ្នែកទី១. ការទទួលខុសត្រូវលើសំណង់អាគារ

សំណង់ គឺជាផ្នែកមួយនៃផលិតផលគ្រឹះក្នុងខឿនសេដ្ឋកិច្ចជាតិដែលមានតួនាទីសំខាន់ក្នុង ការកសាងមូលដ្ឋានសម្ភារៈបច្ចេកទេសសង្គម ហើយក៏ជាការសម្តែងចេញនូវការអភិវឌ្ឍន៍របស់សង្គមក្នុងប្រទេសនីមួយ[16]។ ជាក់ស្តែង ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ យើងក៏សង្កេតឃើញថាវិស័យសំណង់ក៏រីកចម្រើនលូតលាស់ផងដែរ។ ទន្ទឹមនិងនេះ ក៏មានបញ្ហានានាទាក់ទិននិងការគ្រប់គ្រងសំណង់ ដែលជាប់នឹងដីក្នុងករណីសំណង់នោះបានបង្កព្យសនកម្ម ឬប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ។

ហេតុនេះហើយ មាត្រា៧៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីបញ្ហាទាំងនោះ ដោយមានវិការៈដែលកើតចេញពីសំណង់ដែលជាប់នឹងដីនោះ ហើយត្រូវមានការទទួលខុសត្រូវចំពោះការខូតខាតទាំងឡាយពីកម្មសិទ្ធិករ និងអ្នកគ្រប់គ្រងសំណង់នោះដោយសាមគ្គីដែលត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឲ្យមានវិការៈនៃការសាងសង់ ឬគ្រប់គ្រង។ ប៉ុន្តែអ្នកគ្រប់គ្រងអាចរួចផុតពីការទទួលខុសត្រូវបានកាលណាមានភស្តុតាងបញ្ជាក់ថា ខ្លួនបានធ្វើការគ្រប់គ្រងដោយត្រឹមត្រូវ។

### កថាភាគទី១. ករណីការបាក់បែក ឬដួលរលំសំណង់អាគារ

យើងអាចលើកយកក្រឹត្យច្បាប់លេខ៣៨ដែលត្រូវបាននិរាករណ៍មកសិក្សាបាន សម្រាប់ជាការពន្យល់បន្ថែមដោយ មាត្រា១២៨នៃក្រឹត្យច្បាប់បានចែងថា កម្មសិទ្ធិករ ត្រូវទទួលខុសត្រូវចំពោះការខូតខាតដែលកើតឡើងដល់អ្នកដទៃដោយសារទ្រព្យរបស់ខ្លួន ប្រសិនបើការខូតខាតនោះបណ្តាលមកអំពីការខ្វះការថែទាំ ខ្វះការត្រួតពិនិត្យ ឬក៏ដោយសារសំណង់របស់ខ្លួនសង់មិនបានត្រឹមត្រូវល្អ។

[16] សួស ចំរើន, គ្រប់គ្រងសំណង់ (២០០៣)។

ចំណុចនេះបានបង្ហាញពីកំហុសរបស់អ្នកគ្រប់គ្រងដែលអ្នកជាកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងដែលមិនមែនជាកម្មសិទ្ធិករបណ្ដាលឲ្យមានព្យសនកម្មកើតឡើងដល់សំណង់របស់អ្នកដ៏ទៃ បានន័យថាកំហុសរបស់អ្នកគ្រប់គ្រងជាកម្មសិទ្ធិករឬអ្នកគ្រប់គ្រងមិនមែនជាកម្មសិទ្ធិករ ជាហេតុធ្វើឲ្យមានការខូចខាតកើតឡើង នោះត្រូវតែសងសំណងការខូចខាត។

## ១. លក្ខខណ្ឌនាំឲ្យមានការទទួលខុសត្រូវ

### ១.១. ករណីសំណង់អាគារមានវិការៈ

ការបាក់បែក ឬដួលរលំសំណង់អគារ អាចបណ្ដាលមកពីសំណង់អាគារមានវិការៈ។ វាទាក់ទងទៅនិងបញ្ហាវិការៈនៃការសាងសងអាគារ រឺ សំណង់របស់ស្ថាបត្យករ ឬសហគ្រិនដែលសាងសង់អគារ ដោយមិនស្របទៅនិងបច្ចេកទេសក្នុងការសាងសង់ ឬបញ្ហាគុណភាពដែលអាចបង្កឲ្យមានការខូចខាតកើតឡើង ក្នុងនោះអាចមានការដួលរលំ ឬបាក់ស្រុតមួយផ្នែក ឬទាំងស្រុងដែលនាំឱ្យមានព្យសនកម្មកើតឡើងដល់អ្នកដទៃ[17]។ ប្រសិនបើការដួលរលំនៅឬបាក់ស្រុតមួយផ្នែក ឬទាំងស្រុងនោះមិនបានបណ្ដាលឱ្យមានការខូចខាតដល់អ្នកដទៃទេគឺគ្មានការទទួលខុសត្រូវឡើយ។

ករណីអ្នកគ្រប់គ្រងជាកម្មសិទ្ធករគាត់ អាចប្ដឹងទាមទារសំណងពីអ្នកសាងសង់បាន បើសិនជាសំណង់មានវិការៈដែលជាកំហុសអ្នកសាងសង់និងបណ្ដាលឱ្យមានផ្ទះព្យសនកម្ម ប៉ុន្ដែជាគោលការណ៍កម្មសិទ្ធករត្រូវទទួលខុសត្រូវលើការខូចខាតជាមុនសិន។ ចំណែកឯ ករណីអ្នកគ្រប់គ្រងមិនមែនជាកម្មសិទ្ធិករ គឺកម្មសិទ្ធិករនិងអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវដោយសាមគ្គី[18]។

### ១.២. ការធ្វេសប្រហែសនៃការសាងសង់

ករណីការធ្វេសប្រហែសនៃការសាងសង មានភាពស្រដៀងគ្នាទៅនិងវិការនៃការសាងសង់ដែរ ដោយហេតុថាវាបង្ហាញពីកំហុសរបស់អ្នកសាងសង់ ដែលមានភាពធ្វេះថ្លោយក្នុងការបំពេញការងារ តួនាទីរបស់ខ្លួនមិនយកចិត្តទុកដាក់ ហើយបណ្ដាលឲ្យសំណង់មានវិការៈ។ ហេតុនេះ បើសិនណាជាមានការខូចខាតប៉ះពាល់ដល់អ្នកដទៃ ដែលបណ្ដាលមកពីវិការៈនៃសំណង់ កម្មសិទ្ធិករ អាចធ្វើការប្ដឹងទាមទារសំណងនៃព្យសនកម្មវិញបានបន្ទាប់ពីខ្លួនបានចជួសជុលការខូចខាតដល់ជនរងគ្រោះរួចហើយ។

[17] ញឹក វុទ្ធី, នីតិកាតព្វកិច្ច២ (២០២១)។

[18] ញឹក វុទ្ធី, នីតិកាតព្វកិច្ច២ (២០២១)។

## ២. ការរួចផុតពីការទទួលខុសត្រូវ

ការរួចផុតពីការទទួលខុសត្រូវ គឺជាភាពគ្មានកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង។ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង អាចអាចរួចផុតពីការទទួលខុសត្រូវបាន លុះត្រាតែ គាត់មានភ័ស្តុតាងថាគាត់បានគ្រប់គ្រងដោយត្រឹមត្រូវ[19] ហើយជនរងគ្រោះមិនអាចបញ្ជាក់បង្ហាញពីភ័ស្តុងក្នុងការដាក់បន្ទុក។ ហេតុនេះ អ្នកទទួលខុសត្រូវត្រូវបង្ហាញភ័ស្តុតាមពីភាពគ្មានកំហុសរបស់ខ្លួន ទើបរួចផុតពីការទទួលខុសត្រូវ ដែលអាចជាករណីប្រធានសក្តិ ឬជាកំហុសរបស់ជនរងគ្រោះ។

### ២.១. ករណីប្រធានសក្តិ

ការខូចខាតដែលបណ្តាលមកពីប្រធានសក្តិ អ្នកប្រព្រឹត្តមិនត្រូវបានទទួលខុសត្រូវទេពីព្រោះករណីប្រធានសក្តិ សំដៅដល់ព្រឹត្តិការណ៍នៃគ្រោះធម្មជាតិ ហើយមិនអាចជំនះបាន។ ដូចជាករណីខ្យល់ព្យុះ ទឹកជំនន់ជាដើម ដែលបានបណ្តាលឲ្យសំណង់ទទួលរងនូវការខូចខាតដោយស្ថិតនៅក្នុងអំឡុងពេលសាងសង់ដូចជាមានការបាក់ ឬស្រុតផ្នែកណាមួយនៃសំណង់ ហើយក៏បានធ្វើឲ្យអ្នកជិតខាងរងរបួស ករណីនេះអាចឲ្យកម្មសិទ្ធិករ ឬក្រុមហ៊ុនសំណង់ ឬអ្នកម៉ៅការសំណង់រួចផុតពីការទទួលខុសត្រូវបាន ដោយសារតែការខូចខាតដែលបានកើតឡើងនេះមិនមែនកើតចេញពីកំហុសរបស់ក្រុមហ៊ុនសំណង់ ឬអ្នកម៉ៅការឡើយ តែវាបណ្តាលមកពីគ្រោះទឹកជំនន់ឬខ្យល់ព្យុះដែលកើតឡើង។

### ២.២. កំហុសជនរងគ្រោះ

ការខូចខាតខ្លះបណ្តាលមកពីកំហុសរបស់ជនរងគ្រោះខ្លួនឯង ដូចករណីមានអាគារមួយដែលកំពុងសាងសាង់ហើយអាគារដែលគេកំពុងសាងសង់នោះ ក៏បានដាក់បម្រាមថា គ្រោះថ្នាក់ ហាមចូលបើគ្មានភារៈកិច្ច ប៉ុន្តែ ថ្ងៃមួយចំនិងថ្ងៃឈប់សម្រាក ក្មេងៗមួយក្រុមបានលួចចូលទៅលេងកន្លែងការដ្ឋានសាងសងនោះស្រាប់តែមានបំណែកដុំឥដ្ឋនៃអាគារដែលសាងសងមិនមានបច្ចេកទេសត្រឹមត្រូវ បានធ្លាក់ចំបណ្តាលឲ្យបែកក្បាល។ ថ្វីបើអាគារនោះមានវិការៈក៏ពិតមែនតែអ្នកគ្រប់គ្រងបានដាក់បម្រាបក្នុងការហាមឃាត់មិនឲ្យចូលចំពោះជនគ្មានភារកិច្ច ដូចនេះហើយវាជាកំហុសរបស់ជនរងគ្រោះដែលបានលួចចូលកន្លែងគេហាមឃាត់ ឯអ្នកគ្រប់គ្រងពុំមានកាតព្វកិច្ចជួសជុលការខូចខាតឡើយ។

## កថាភាគទី២. ករណីអាគារមានអគ្គីភ័យ

[19] មាត្រា៧៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១. លក្ខខណ្ឌនាំឲ្យមានការទទួលខុសត្រូវ

### ១.១. សំណង់ដែលមានម្ចាស់គ្រប់គ្រង

ក្នុងករណីអាគារមានអគ្គីភ័យ បើសិនណាជាអាគារនោះមានកម្មសិទ្ធិករដែលជាអ្នកកាន់កាប់ ឬមានអ្នកគ្រប់គ្រងទើបមានការទទួលខុសត្រូវ ចំពោះការខូចខាតលើជនរងគ្រោះ ដោយអាចជាមូលហេតុមកពីការធ្វេសប្រហែសក្នុងការគ្រប់គ្រងវត្ថុ ឬរបស់ដែលអាចបង្កឲ្យមានភ្លើងឆាបឆេះ។ ផ្ទុយទៅវិញ បើអាគារ ឬសំណង់នោះពុំមានអ្នកកាន់កាប់ទេ នោះពុំមានជនណាមួយធ្វើការរ៉ាប់រងព្យសនកម្មឡើយ។

### ១.២. សំណង់ជាប្រភពនៃអគ្គិភ័យ

ក្នុងលក្ខខណ្ឌមួយទៀតនៃការទទួលខុសត្រូវករណីអាគារមានអគ្គីភ័យ លុះត្រាណាអាគារ ឬសំណង់នោះជាប្រភពនៃភ្លើងឆេះ។ ដូចដែលបានបញ្ជាក់ខាងលើ កាលណាកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងមិនយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ បណ្តាលឲ្យមានអគ្គិភ័យកើតឡើង ហើយបានឆេះរីករាលដាលដល់ផ្ទះអ្នកជិតខាង នោះផ្ទះដែលឆេះដំបូងជាប្រភពនៃអគ្គិភ័យ។

ក្នុងករណី ម្ចាស់ផ្ទះ ក បានអុជធូបរួចចេញទៅផ្សារបាត់ ហើយកំទេចធូបនោះបានធ្វើឲ្យភ្លើងឆេះផ្ទះដូច្នេះផ្ទះនោះគឺជាប្រភពនៃភ្លើងនិងត្រូវទទួលខុសត្រូវបើភ្លើបានឆេះប៉ះពាល់ដល់ទ្រព្យអ្នកដទៃទៀត។

## ២. ការរួចផុតពីការទទួលខុសត្រូវ

ការរួចផុតពីការទទួលខុសត្រូវ ភាពគ្មានកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងវាអាចជាករណីប្រធានសក្តិ តតិយជនផ្ទះ ឬសំណង់នោះមិនមែនជាប្រភពនៃភ្លើងជាដើម។

### ២.១. សំណង់អាគារដែលមិនមែនជាប្រភពនៃអគ្គិភ័យ

ចំពោះអាគារមិនមែនជាប្រភពនៃភ្លើង គឺដំបូងឆេះផ្ទះទី១ បន្ទាប់មកផ្ទះលេខ២ បន្ទាប់មកទៀតផ្ទះលេខ៣ ទោះបីជាផ្ទះលេខ២ ជាប្រភពនៃភ្លើងដែលនាំអោយផ្ទះលេខ៣ ឆេះពិតមែន ប៉ុន្តែវាមិនមែនជាប្រភពដើមទេផ្ទះលេខ២ បានឆេះដោយផ្ទះលេខ១ដែរ។ ដូចនេះ ផ្ទះលេខ១ជាអ្នករ៉ាប់រងទាំងស្រុង លើកលែងតែមានមូលហេតុខាងក្រៅចូលរួម។

### ២.២. ករណីប្រធានសក្តិ

ប្រធានសក្តិ សំដៅដល់ព្រឹត្តិការណ៍ទាំងឡាយណាដែលកើតឡើងក្រៅពីឆន្ទៈហើយមិនអាចប៉ាន់ស្មានទុកជាមុន និងមិនអាចជុំនះបាន[20]។ ឧបមាថា មានរន្ទះបាញ់ផ្ទះ លោក ក បណ្តាលឱ្យឆេះរាលដាលដល់ផ្ទះលោក ខ។ ហេតុនេះលោក ក មិនជានាខុសត្រូវលើការខូចខាតរបស់លោក ខ ឡើយ ព្រោះថាវាជារឿងដែលមិនអាចទប់ស្កាត់បាន ហើយលោកក៏ជាជនរងគ្រោះដោយសារករណីប្រធានសក្តិដែរ។

**២.៣. តតិយជន**

បើសិនជាមានគេលួចដុតផ្ទះរបស់ លោក ក ហើយវាបានឆេះរីករាលដាលដល់ផ្ទះ អ្នកនាង ខ នោះលោក ក អាចរួចផុតពីការទទួលបាន ដោយហេតុថាករណីនេះពុំមែនជាកំហុសរបស់គាត់ទេ តែវាជាកំហុសរបស់ជនទី៣ដែលបានលួចដុតផ្ទះ ហើយជននោះទើបជាអ្នកទទួលខុសត្រូវពិតប្រាកដ។

## ផ្នែកទី២. ការទទួលខុសត្រូវលើគ្រឿងសម្អាង

បច្ចុប្បន្ននេះ យើងសង្កេតឃើញថាការប្រើប្រាស់គ្រឿងសម្អាងមានការពេញនិយមច្រើន ដោយបានកត់សម្គាល់ត្រង់ចំណុចនេះហើយ ទើបកិច្ចការស្រាវជ្រាវមួយនេះបានលើកយកការទទួលខុសត្រូវលើគ្រឿងសម្អាងមកធ្វើការសិក្សាដើម្បីផ្តល់ជាចំណេះដឹងផ្នែកគតិយុត្តបន្ថែម ថាតើនរណាជាអ្នកទទួលខុសត្រូវ និងអាចរួចផុតពីការទទួលខុសត្រូវបានឬទេ បើអ្នកប្រើប្រាស់ទទួលរងនូវការខូតខាតពីការប្រើប្រាស់វា។

### កថាភាគទី១. គ្រឿងសម្អាង

ទន្ទឹមនិងនេះ មូលហេតុក្នុងការយកគ្រឿងសម្អាងយកមកធ្វើការសិក្សា ដោយមានបំណងចង់អោយមនុស្សគ្រប់រូបស្គាល់ពីរបស់ថែរក្សា សម្រស់ និងយល់ដឹងផលវិបាកនៃការប្រើប្រាស់របស់ក្លែងក្លាយ ខូចគុណភាព និងការប្រើប្រាស់មិនត្រឹមត្រូវតាមក្បួនខ្នាត។ ជាការពិតណាស់មនុស្សគ្រប់រូបតែងចង់ស្អាតចង់ល្អ ហើយអ្នកខ្លះក៏ហ៊ានចំណាយលុយច្រើនដើម្បីថែរក្សាសម្រស់ផងដែរ។ យើងគួរស្វែងរកផលិតផលមួយអោយត្រូវតាមស្បែកមុខរបស់យើង និងផលិតផលសុទ្ធ។ កាលណាដែរយើងទិញប៉ះចំរបស់ក្លែងក្លាយ ខូចគុណភាព វាធ្វើអោយប៉ះពាល់ដល់ស្បែកនិងសុខភាពរបស់យើងនូវថ្ងៃខាងមុខ។ ដូច្នេះយើងគប្បីទិញផលិតផលណាដែរត្រូវនិងស្បែករបស់យើង ហើយស្វែងរកផលិតផលសុទ្ធ និងមើលកាលបរិច្ឆេទអោយបានត្រឹមត្រូវ របៀបប្រើប្រាស់ផងដែរ។ បើយើងទិញផលិតផលដែលសុទ្ធសាកសមនិងស្បែករបស់យើង ហើយយើងប្រើប្រាស់អោយសាកសមនិង

[20] សន្ធានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ១០០, ទំព័រ១៤។

ស្បែករបស់យើងទៀតនោះ វានិងមិនមានផលរំខានដល់ថ្ងៃខាងមុខហើយមិនប៉ះពាល់ដល់សុខភាពទេ ហើយនិងមិនខាតពេលវេលាព្យាបាល។

## ១. និយមន័យ

### ១.១. គ្រឿងសម្អាង

គ្រឿងសម្អាង សំដៅដល់ផលិតផល ដែលផ្សំឡើងដោយសារធាតុគីមី ជីវផលិតផលរុក្ខជាតិ ឬសិលាជាតិ សម្រាប់ប្រើលើបណ្តាលផ្នែកខាងក្រៅនៃខ្លួនមនុស្ស (ស្បែក សក់ ក្រចក បបូរមាត់ និងផ្នែកខាងក្រៅអវយវៈភេទ) ឬប្រើលើធ្មេញ និងជាលិកាទន់នៃក្រអូមមាត់ ក្នុងគោលបំណង សំអាត ការពារ ថែរក្សា ធ្វើឱ្យក្រអូប ផ្លាស់ប្តូររូបភាព ខាងក្រៅ និងបំបាត់ក្លិនខ្លួន[21]។

### ១.២. អ្នកផលិតគ្រឿងសម្អាង

យោងតាមខ្លឹមសារនៃមាត្រា ៧៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើម អ្នកនាំចូល និងបុគ្គលដែលបានដាក់សញ្ញានៃនាមករណ៍របស់ខ្លួននៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាអ្នកផលិត។ ហេតុនេះ បុគ្គលទាំងឡាយណាដែលបានបង្កើត គ្រឿងសម្អាងដោយរូបមន្តខ្លួនឯង ឬ ធ្វើការនាំចូលផលិតផល ឬបានដាក់សញ្ញានៃនាមករណ៍របស់ខ្លួននៅលើគ្រឿងសម្អាង បុគ្គលនោះនឹងត្រូវចាត់ទុកថាជាអ្នកផលិតគ្រឿងសម្អាង។

## កថាភាគទី២. ការទទួលខុសត្រូវរបស់អ្នកផលិតគ្រឿងសម្អាង

នៅក្នុងច្បាប់បានកំណត់អំពីការទទួលខុសត្រូវផលិតផលរបស់អ្នកផលិតវត្ថុ ដោយវត្ថុនោះគឺជាចលនវត្ថុដែលត្រូវបានផលិតឡើងមានវិការៈ ហើយបានបង្កឲ្យអន្តរាយដល់អ្នកប្រើប្រាស់។ ប៉ុន្តែនៅក្នុងច្បាប់ពុំបានបកស្រាយអំពីការភាពមានវិការៈនៃផលិតផលទេ ប៉ុន្តែយើងអាចនិយាយបានថាវាជាភាពមិនប្រក្រតីនៃផលិតផលដោយសារផលិតកម្មមិនល្អ[22]។

ដោយឡែក គ្រឿងសម្អាងដែលធ្វើអាជីវកម្មនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផលិតក្នុងសហគ្រាស ដែលបានអនុវត្តតាមគោលការណ៍អនុវត្តផលិតកម្មល្អ ឬគោលការណ៍អនុវត្តផលិតកម្មល្អអប្បបរមាក្នុង

[21] មាត្រា៣ អនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងសម្អាង ឆ្នាំ២០០៨។

[22] មើលមាត្រា៧៥១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ការផលិតគ្រឿងសម្អាង ដែលទទួលយកបានដោយស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងគ្រឿងសម្អាង[23]។ ជាពិសេសទៀតនោះ ផលិតផលគ្រឿងសម្អាងទាំងអស់ត្រូវបង្កើតឡើងដោយគោរពតាមលក្ខខណ្ឌ ដែលត្រូវមានគុណភាព និងសុវត្ថិភាព ដោយមិនបង្កគ្រោះថ្នាក់ ដល់អ្នកប្រើប្រាស់ និងត្រូវមានស្លាកសញ្ញា ព្រឹត្តិបត្រព័ត៌មានណែនាំអំពីរបៀបប្រើប្រាស់ ការរក្សាទុក និងប្រុងប្រយ័ត្នក្នុងការប្រើ[24]។

ទាក់ទិននិងបញ្ហានេះ ក្នុងករណីគ្រឿងសម្អាងដែលបានបង្កើតឡើងដោយផ្ទុយទៅនិងលក្ខខណ្ឌនៃការធានាសុវត្ថិភាពគ្រឿងសម្អាង មានដូចជាគ្រឿងសម្អាងក្លែងក្លាយ និងគ្រឿងសម្អាងខូចគុណភាពបានបង្កគ្រោះថ្នាក់ដល់អ្នកទិញផលិតផលនោះយកទៅប្រើប្រាស់ អ្នកផលិតគ្រឿងសម្អាងត្រូវធានារ៉ាប់រងការខូចខាតចំពោះជនរងគ្រោះ។

## ១. ការចែកចាយគ្រឿងសម្អាងក្លែងក្លាយ

យោងតាមមាត្រា៣ កថាខណ្ឌទី២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រង់គ្រឿងសម្អាង បានកំណត់ថា គ្រឿងសម្អាងក្លែងក្លាយ ឬក្លែងបន្លំ សំដៅ ដល់ផលិតផល ដែលមានសារធាតុផ្សំមិនគ្រប់ចំនួន ខុសកម្រិត ឬមិនត្រឹមត្រូវតាមសមាសធាតុផ្សំ ដែលផលិតករបានរៀបរាប់ ក្នុងឯកសារទុកនៅក្រុមហ៊ុន ឬរូបមន្ត ដែលបានកំណត់លើស្លាកសញ្ញផលិតផល ដែលផលិត ឬវេចខ្ចប់ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលគ្មានអាជ្ញាប័ណ្ណពីស្ថាប័នមានសមត្ថកិច្ចផលិតផលដែលមានស្លាកសញ្ញ ឬមានការវេចខ្ចប់ របៀបបង្ហាញរចនាបថ អត្តសញ្ញាណស្រដៀងនឹងគ្រឿងសម្អាងមួយផ្សេងទៀត ដែលជាគ្រឿងសម្អាងពិត ។

ប្រសិនបើយើងនិយាយអំពីការយករបស់ក្លែងក្លាយទៅប្រើប្រាស់ ពេលដែលលាបទៅជ្រាបចូលក្នុងស្បែក អាចមានផលប៉ះពាល់ច្រើនដល់សុខភាពដូចជា ធ្វើឲ្យលោកស្បែក កើតមហារីកស្បែក និងអាចធ្វើកើតជាជំងឺកមរមាស់ ឬជួនកាលធ្វើឱ្យប្រតិកម្មស្បែកព្យាបាលមិនជា និងគ្រោះថ្នាក់ដល់ជីវិតក៏មាន។ ចំពោះករណីនារីម្នាក់ គាត់បានទិញលេលាបខ្លួនពីក្នុងផ្សារនៅកន្លែងលក់គ្រឿងក្រអូបមួយកន្លែង ដោយសារតែគាត់ឃើញតម្លៃថោកជាងទីផ្សារគាត់ក៏សម្រេចចិត្តទិញ។ ស្រាប់តែគាត់ប្រើបានមួយរយៈ ស្បែករបស់គាត់ក៏ចាប់ផ្តើមឡើងក្រហម និងរមាស់ ហើយគាត់ក៏បានយកផលិតផលនោះទៅសួរដល់ក្រុមហ៊ុនផ្ទាល់ទើបដឹងថារបស់នោះជារបស់ក្លែងក្លាយ។ ក្រុមហ៊ុនមិនមានកាតព្វកិច្ចសងសំណងឡើយ បើផលិតផលនោះមិនមែនជារបស់ខ្លួន ហើយបន្ទុកនេះត្រូវធ្លាក់លើអ្នកលក់។ ដូច្នេះមុននឹងសម្រេចទិញផលិតផលគ្រឿងសម្អាងយកមកប្រើប្រាស់យើងគួរតែ

[23]មាត្រា៨ អនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងសម្អាង ឆ្នាំ២០០៨។

[24] មាត្រា៩ អនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងសម្អាង ឆ្នាំ២០០៨។

ត្រូវមានការប្រុងប្រយ័ត្ននឹងពិនិត្យមើលឱ្យបានច្បាស់ ទីមួយ សង្កេតមើលរូបរាងទំហំទម្ងន់ និងពណ៌របស់ផលិតផលដែលមានលក្ខណៈខុសពីស្តង់ដារ ទីពីរ ការវេចខ្ចប់មិនស្អាតដោយប្រើប្រាស់វត្ថុធាតុដើម គ្មានគុណភាព និងមានគុណភាពទាប ទីបី ការបោះពុម្ពនៅលើស្លាកសញ្ញាមិនច្បាស់ រួមទាំងការពិពណ៌នាមិនត្រឹមត្រូវ និងការសរសេរខុស ទីបួន ការពិពណ៌នាអំពីផលិតផលត្រូវបានបំផ្លើសការពិត ដោយពុំមានរៀបរាប់អំពីធាតុផ្សំ និងមិនមានបញ្ជាក់អាជ្ញាប័ណ្ណ អនុញ្ញាតពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ទីប្រាំ មិនមានការបញ្ជាក់ពីការនាំចូល ឬការផលិត ទីប្រាំមួយ ពុំមានអាសយដ្ឋានរបស់រោងចក្រច្បាស់លាស់ និងចុងក្រោយ តម្លៃមានលក្ខណៈថោកខុសពីធម្មតា។

**២. ការចែកចាយគ្រឿងសម្អាងខូចគុណភាព**

យោងលើមាត្រា៣ កថាខណ្ឌទី៣ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងសម្អាង បានកំណត់ថា គ្រឿងសម្អាងខូចគុណភាព សំដៅដល់ផលិតផល ដែលទុកដាក់មិនត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេស និងផលិតផលដែលហួសកាលបរិច្ឆេទប្រើប្រាស់។ ជាការពិតណាស់ គ្រឿងសម្អាងត្រូវបានផលិតឡើងដោយមានសារធាតុជាច្រើនមុខ ដូច្នេះវាចាំបាច់ណាស់ត្រូវមានការរក្សាទុកដាក់ឲ្យបានយ៉ាងត្រឹមត្រូវដោយពុំទុកឲ្យនៅត្រូវថ្ងៃខ្លាំងពេក ឬមួយក៏ទុកឲ្យនៅកន្លែងត្រជាក់ខ្លាំងពេកដែលជាហេតុបណ្តាលឲ្យខូចគុណភាពរបស់វា។ មួយវិញទៀត ផលិតផលទាំងអស់សុទ្ធតែមានកាលបរិច្ឆេទកំណត់ក្នុងការប្រើប្រាស់ ព្រោះវាមិនអាចរក្សាគុណភាពល្អបានជានិរន្តន៍ឡើយ។ ហេតុនេះ កាលបើវាជិតដល់ថ្ងៃផុតកំណត់ ឬបានផុតកំណត់ហើយនោះ គុណភាពវាចាប់ផ្តើមអន់ថយ ឬប្រើប្រាស់លែងបានតែម្តង។

យ៉ាងណាមិញ ប្រសិនបើក្រុមហ៊ុនលក់ឡេមួយ ហេតុតែផលិតផលនៅសល់ច្រើនក៏ចាប់ផ្តើមលក់បញ្ចុះតម្លៃខ្លាំងដើម្បីអោយឆាប់អស់ ដោយមិនខ្វល់ថាផលិតផលដែលនៅសល់ច្រើននោះខ្លះជិតដល់ថ្ងៃហួសកំណត់ ហើយខ្លះបានផុតកំណត់ ហើយគុណភាពរបស់វាក៏ខូច ឬចុះអន់ថយ និងអាចបណ្តាលឲ្យមានការខូតខាតដល់អ្នកទិញយកទៅប្រើ។ ដូចនេះ ក្រុមហ៊ុនលក់ឡេ ត្រូវតែជួសជុលការខូចខាតដល់ជនរងគ្រោះបើមាន។

## កថាភាគទី៣. ការរួចផុតពីការទទួលខុសត្រូវ

នៅក្នុងច្បាប់ក៏មានការអនុគ្រោះ ឲ្យអ្នកផលិតអាចរួចផុតពីការទទួលខុសត្រូវបានផងដែរ ជុំវិញបញ្ហាដែលមិនអាចប្រមាណនូវភាពមិនប្រក្រតីនៃផលិតផង តាមកម្រិតវិទ្យាសាស្ត្រនៃបច្ចេកទេសដែលមាននៅសម័យនោះ។ ទោះជាយ៉ាងនេះក្តី ជាក់ស្តែងយើងសង្កេតឃើញថាចំណុចនេះវាកម្រនឹងកើតមានឡើង ព្រោះថា

មុនបង្កើតបានជាផលិតផលសម្រេចមួយ គឺត្រូវឆ្លងកាត់ជាច្រើនដំណាក់កាលក្នុងការផលិត ព្រមទាំងមានត្រួតពិនិត្យយ៉ាងម៉ត់ចត់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ច មុននិងធ្វើការចែកចាយដល់អ្នកប្រើប្រាស់។

យ៉ាងណាក៏ដោយ ការរួចផុតពីការទទួលខុសត្រូវអាចធ្វើទៅបាន លុះត្រាវាជាកំហុសអ្នកប្រើប្រាស់ ឬជនរងគ្រោះ និងការយល់ព្រមពីជនរងគ្រោះ។

## ១. កំហុសអ្នកប្រើប្រាស់

ផលិតផលគ្រឿងសម្អាងនីមួយៗដែលចេញលក់នៅទីផ្សារ សុទ្ធតែមានធាតុផ្សំនិងរបៀបប្រើប្រាស់តែបើយើងប្រើប្រាស់ខុសស្តង់ដាវានិងបណ្តាលឲ្យមានបញ្ហាដល់ខ្លួនយើងអ្នកប្រើប្រាស់គ្រឿងសម្អាងឬផលិតផលអ្វីមួយ។ ជាទូទៅ ត្រូវប្រើផលិតផលឲ្យត្រូវតាមស្បែកមុខនិងដងខ្លួនដើម្បីប្រើឆាប់ឃើញប្រសិទ្ធភាព តែសង្កេតឃើញមនុស្សមួយចំនួនពីព្រោះតែពួកគេចង់ឆាប់ឃើញលទ្ធផលខ្លាំងពេក ពួកគេបានប្រើប្រាស់ខុសពីការណែនាំរបស់អ្នកលក់ ឬការសរសេរបង្ហាញប្រាប់នៅលើផលិតផល។ មួយវិញទៀត ការប្រើប្រាស់ផលិតផលច្រើនមុខចូលគ្នាវាក៏អាចឲ្យមានបញ្ហាកើតឡើងដែរ ពីព្រោះធាតុផ្សំខ្លះមិនអាចប្រើចូលគ្នាបានទេហើយវាក៏អាចឲ្យយើងមានបញ្ហាដល់ស្បែកមុខនិងដងខ្លួនទៀតផង។ រាល់ព្យសនកម្មលើរូបរាងកាយទាំងអស់នេះ សុទ្ធតែជាកំហុសរបស់អ្នកប្រើប្រាស់ទាំងស្រុង។

ជាឧទាហរណ៍ បុរស ក បានទិញរបស់ស្រ្កាប់សម្រាប់ខាត់ស្បែកម៉ាក ខ ពីក្នុងផ្សារនៅកន្លែងលក់គ្រឿងសម្អាង អ្នកលក់ក៏បានប្រាប់ពីរបៀបប្រើប្រាស់ហើយនៅលើកំប៉ុងស្រ្កាប់ស្បែកនោះក៏មានសរសេរដូចគ្នាថាក្នុងមួយអាទិត្យគឺស្រ្កាប់ស្បែកបានតែម្តងតែប៉ុណ្ណោះ។ ពេលគាត់បានទិញទៅគឺគាត់មិនបានប្រើប្រាស់ដូចគេប្រាប់និងសរសេរពីរបៀបណែនាំនោះទេ គឺប្រើជាប្រចាំព្រោះដើម្បីឆាប់ឃើញលទ្ធផល ពេលដែលគាត់ប្រើរាល់ថ្ងៃស្បែករបស់គាត់ក៏ចាប់ផ្តើមក្រហមនិងរមាស់ដោយសារតែប្រើប្រាស់មិនដូចអ្វីដែលគេបានណែនាំ។

## ២. ការយល់ព្រមពីជនរងគ្រោះ

ការយល់ព្រមពីជនរងគ្រោះ មានន័យថាជាការដែលព្រមព្រៀង និងព្រមទទួលយកនូវការខូចខាតដែលអាចកើតមានរបស់ជនរងគ្រោះ។ ប៉ុន្តែ វាមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល[25]។ រឿងក៏អាចលើកលែងបាន អ្នក

[25] មាត្រា៧៥៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលត្រូវតែមានមានការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ។

ដូចជាក្នុងករណីថា កញ្ញា ក ជាអ្នកលក់គ្រឿងសម្អាង នៅពេលដែលបាននាំចូលផលិតផលថ្មី ក៏មាននារីម្នាក់ដែលជាមិត្តភក្តិតែងសុំ និងស្មគ្រ័ចិត្តសាកផលិតផលទាំងអស់ដោយខ្លួនឯង ដោយការចង់ប្រើផលិតផលថ្មីមុនគេ ស្រាប់តែប្រើបានចំនួនបីថ្ងៃស្រាប់តែមុខឡើងរោល ពីព្រោះតែមានធាតុផ្សំខ្លះមិនត្រូវស្បែកមុខរបស់ខ្លួន។ ករណីនេះការយល់ព្រមពីជនរងគ្រោះដោយខ្លួនឯង។

## ផ្នែកទី៣. ការទទួលខុសត្រូវលើវត្ថុមានគ្រោះថ្នាក់

ដោយផ្អែកលើមាត្រា៧៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ យើងឃើញថា វត្ថុដែលមានកំណត់នៅក្នុងនេះសុទ្ធសឹងតែជាប្រភេទវត្ថុ ដែលមានអត្រាគ្រោះថ្នាក់ខ្ពស់ ដូចជាគ្រឿងផ្ទុះវត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមី ដែលមានជាតិពុលអតិសុខុមប្រាណឧត្បាត ឬគ្រឿងដែលមានកម្រិតគ្រោះថ្នាក់ផ្សេងទៀត ឬថយន្ត និងគ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងៗ។ ដូចនេះ ប្រសិនបើវត្ថុទាំងនោះបានបង្កឲ្យមានការខូតខាតដល់អ្នកដទៃ នោះកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង ត្រូវទទួលខុសត្រូវដោយធានាក្នុងការសងលើការខូតខាតទាំងនោះ។ ប៉ុន្តែ ក្នុងករណីប្រធានសក្តិ ការគ្រប់គ្រងវត្ថុដោយគ្មានវិការៈ ហើយការខូចខាតបណ្តាលមកពីអំពើរបស់ជនរងគ្រោះ ឬតតិយជនកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងក៏មានសិទ្ធិក្នុងការតវ៉ាចំពោះការទំលាក់បន្ទុកនេះបានដែរ។

ការទទួលខុសត្រូវលើវត្ថុមានគ្រោះថ្នាក់ក្នុងផ្នែកទី៣នេះនឹងធ្វើការសិក្សាលើពីរចំណុចធំៗគឺ ការទទួលខុសត្រូវលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងថ្នាំគីមីកសិកម្ម (ថ្នាំ និងជីកសិកម្ម)។

### កថាភាគទី១. ការទទួលខុសត្រូវលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

ការប្រព្រឹត្តបទល្មើស ជាទូទៅគេតែងតែសង្កេតឃើញថាជនល្មើសភាគច្រើនបានប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវក្នុងការសម្រេចនូវបទល្មើស មិនថាបទល្មើសតូច ឬបទល្មើសឧក្រិដ្ឋកម្មធំៗដែលកើតមានឡើងនៅក្នុងសង្គម។ គួររព្ញកផងដែរថា អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ជាវត្ថុមានគ្រោះថ្នាក់ដែលអាចបង្កផលប៉ះពាល់យ៉ាងចំពោះអាយុជីវិតមនុស្ស សត្វក៏ដូចជាបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់របស់សង្គមជាតិ។ អាស្រ័យហេតុនេះហើយ ទើបចាំបាច់ត្រូវមានច្បាប់គ្រប់គ្រង និងកំណត់ឱ្យបានច្បាស់លាស់ចំពោះបុគ្គលដែលមានសិទ្ធិកាន់កាប់ និងប្រើប្រាស់អាវុធទាំងនោះ ព្រមទាំងត្រូវកំណត់នូវស្ថានទំងន់ទោសទៅតាមទំហំនៃព្យសនកម្មចំពោះជនទាំងឡាយណាដែលបានប្រើប្រាស់អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវផ្ទុយពីការកំណត់របស់ច្បាប់។

## ១. និយមន័យ

### ១.១. អាវុធ

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឲ្យមានរបួស[26]។

ដោយឡែកនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ បានកំណត់ថាអាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតម្លើង ដែលអាច ប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ[27]។

### ១.២. គ្រឿងផ្ទុះ និងគ្រាប់រំសេវ

គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈដែលគេផលិត ឬ កែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិ[28]។

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ មាត្រា៣ ចំណុច គ ក៏បានកំណត់បន្ថែមពី អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដ៏ទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្ត្រ គឺសំដៅដល់សារធាតុដែលគេផលិត ឬ កែច្នៃតម្លើង អាចបង្កគ្រោះថ្នាក់ដល់ សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និង បរិស្ថាន។

## ២. លក្ខខណ្ឌនៃការទទួលខុសត្រូវ

នៅក្នុងច្បាប់ដដែលនេះបានហាមដាច់ខាតនូវការប្រើប្រាស់ និងកាន់កាប់គ្រប់ទម្រង់ដែលមានការជួញដូរ ការស្តុកទុក ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការឱ្យខ្ចី ការផ្ទេរ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា។ វាជាកំហុសដែលផ្ទុយទៅនិងច្បាប់កំណត់ ប៉ុន្តែទាក់ទិនទៅនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី បើសិនណាជាកំហុសនោះពុំបានបង្កការខូចខាតដល់ជនណាមួយ គឺគ្មានការទទួលខុសត្រូវទេ។

ហេតុនេះហើយ យើងនឹងធ្វើការសិក្សាទៅលើអំពើរបស់អ្នកកាន់កាប់វត្ថុទាំងនោះ ដោយមានកំហុសក្នុងការប្រើប្រាស់ និងកំហុសក្នុងការគ្រប់គ្រង និងថែរក្សា។

[26] មាត្រា៨១ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
[27] មាត្រា៣ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ២០០៥។
[28] មាត្រា៣ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ២០០៥។

### ២.១. កំហុសក្នុងការប្រើប្រាស់

ជនទាំងឡាយណាដែលមានតួនាទីជាកងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រីមុខងារសាធារណៈ មន្ត្រីតុលាការ និងមន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ មានសិទ្ធិក្នុងការប្រើប្រាស់ កាន់កាប់ អាវុធ។ ក៏ប៉ុន្តែ មិនមែនមានន័យថាអាចប្រើប្រាស់បានតាមតែអំពើចិត្តនោះទេ។ បើសិនណាជនទាំងអស់នោះបានប្រើប្រាស់ដោយខុសច្បាប់ ដែលអាចមានដូចជាការប្រើប្រាស់កាំភ្លើងមិនមែនក្នុងពេលចុះបេសសកម្ម ឬនៅតាមទីប្រជុំជនជាដើមនោះហើយបានបង្កឱ្យអ្នកដទៃមានរបួសស្នាមជននោះត្រូវទទួលបន្ទុកទទួលខុសត្រូវ។ ដូចករណីលោក ក នគរបាល បានទៅក្លិបកំសាន្តមួយកន្លែង ព្រមទាំងបានយកកាំភ្លើងខ្លីមួយដើមយកទៅតាមខ្លួនផងដែរ។ បន្ទាប់មក នៅពេលផឹកស្រវឹងខ្លាំងពេក លោក ក ក៏បានដកកាំភ្លើងនោះចេញហើយបានបាញ់ត្រូវចំជើងរបស់មិត្តភិក្តគាត់។ នេះជាការប្រើប្រាស់មិនត្រូវតាមតួនាទី និងកាលៈទេសៈដែលវាផ្ទុយទៅនិងអ្វីដែលច្បាប់បានកំណត់ ហេតុនេះលោក ក ក៏ត្រូវទទួលខុសត្រូវទៅតាមច្បាប់កំណត់ផងដែរ។

### ២.២. កំហុសក្នុងការគ្រប់គ្រង និងថែរក្សា

ចំពោះជនដែលមានសិទ្ធិក្នុងការកាន់កាប់និងប្រើប្រាស់អាវុធ ក៏ប៉ុន្តែមានភាពខ្វះខាតក្នុងការគ្រប់គ្រងវត្ថុគ្រោះថ្នាក់នោះដោយការថែរក្សា ទុកដាក់មិនបានត្រឹមត្រូវ ឬមូលហេតុផ្សេងៗ ហើយបណ្តាលអោយអ្នកដទៃមានគ្រោះថ្នាក់ ត្រូវទទួលខុសត្រូវទៅតាមផ្លូវច្បាប់។ ដូចក្នុងករណី នាយឆ្មាំកាន់ឃ្លាំងដាក់រំសេវមួយកន្លែងបានដក់បារីនៅក្នុងពេលខ្លួនកំពុងយាម ដោយមិនបានចាប់អារម្មណ៍ថាខ្យល់បានបក់នាំកម្ទេចកន្ទុយបារីចូលឃ្លាំងដែលបង្កឲ្យមានការឆាបឆេះ និងផ្ទុះប៉ះពាល់ដល់ប្រជាជននៅជុំវិញនោះទៀតផង។ នេះជាកំហុសរបស់នាយឆ្មាំដែលមានការធ្វេសប្រហែសក្នុងការថែរក្សាវត្ថុទាំងអស់នោះ

ម្យ៉ាងវិញទៀត យោងតាមមាត្រា២១ ច្បាប់ស្តីពីការគ្រប់គ្រង់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ជនណាដែលធ្វេសប្រហែសឱ្យជនដទៃយកអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទដែលខ្លួនកាន់កាប់ទៅប្រើប្រាស់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំដល់ ២ឆ្នាំ និងទោសពិន័យជាប្រាក់ចាប់ពី៧០០.០០០(ចិត្តសិបម៉ឺនរៀល) ២.០០០.០០០(ពីរលានរៀល)។ ជាក់ស្តែង ក្នុងច្បាប់ក៏បានកំណត់ថាជនស៊ីវិល ឬប្រជាជនសាមញ្ញជាបុគ្គលដែលច្បាប់បានអនុញ្ញាតឱ្យមានសិទ្ធិប្រើប្រាស់អាវុធឡើយ។ ការណ៍ដែលជនស៊ីវិលបានប្រើប្រាស់ហើយជាពិសេសបានធ្វើឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ ជននោះត្រូវទទួលបន្ទុកទទួលខុសត្រូវលើការខូតខាតរបស់ជនរងគ្រោះ។ ការប្រើប្រាស់អាវុធ ដោយខុសច្បាប់បែបនេះ ត្រូវរ៉ាប់រងទាំងសំណងរដ្ឋប្បវេណី ព្រមទាំងសំណងផ្នែកព្រហ្មទណ្ឌដែលពុំអាចដោះបន្ទុកបានទេ។ ឧបមាថា លោក ក បានយកកាំភ្លើរបស់កូនគាត់ឈ្មោះលោក ខ

ដែលជាប៉ូលីស ទៅបង្ហាញមិត្តភក្តិរបស់គាត់ឈ្មោះលោក គ ហើយមិនបានប្រយ័ត្ន ក៏រាកៃបាញ់ចំលោក គ។ ករណីនេះ លោក ខ ជាជនដែលពុំមានសិទ្ធិកាន់កាប់កាំភ្លើងនោះទេ ប៉ុន្តែ គាត់បានយកវាទៅប្រើសាកឱ្យគេមើល និងធ្វើឱ្យមានគ្រោះថ្នាក់ថែមទៀតផង។

## ៣. មូលហេតុនាំឲ្យរួចផុតពីការទទួលខុសត្រូវ

### ៣.១. ការរាយការណ៍ក្នុងករណីបាត់

ចំពោះការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងពីរករណីគឺករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលកំពុងកាន់កាប់ ប្រើប្រាស់ និងការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលបានស្តុកទុកក្នុងឃ្លាំង។ ករណីបាត់នៅពេលដែលកំពុងប្រើប្រាស់ និកាន់កាប់ ត្រូវរាយការណ៍ទៅប៉ុស្តិ៍កងរាជអាវុធហត្ថ នៅទីកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮអំពីការបាត់នោះបានកើតឡើងនៅក្រៅអង្គភាពដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍។ ក្នុងករណីគ្មានសាក្សីសមត្ថកិច្ចនៅកន្លែងកើតហេតុត្រូវចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់។ ចំណែកឯករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលស្តុកទុកក្នុងឃ្លាំងរបស់អង្គភាពនាយឆ្មាំ ឬ អ្នកទទួលខុសត្រូវថែរក្សាត្រូវរាយការណ៍ដល់មេបញ្ជាការ ឬ ប្រធានអង្គភាព ហើយមេបញ្ជាការ ឬ ប្រធានអង្គភាព ត្រូវចាត់វិធានការត្រួតពិនិត្យស្រាវជ្រាវជាបន្ទាន់។ ការរាយការណ៍ក្នុងករណីទាំងពីរ ត្រូវមិនលើសពី ២៤(ម្ភៃបួន)ម៉ោងក្រោយដឹងថាបាត់ ហើយចំពោះពីការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទខាងលើនេះ បុគ្គលមានសមត្ថកិច្ចត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិត ទាក់ទងនឹងប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និង កាលៈទេសៈនៃការបាត់[29]។

### ៣.២. ការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

ការការពារជាធម្មានុរូប គឺសំដៅទៅលើអំពើ រំលោភដែលពុំអាចជៀសវាងបានដើម្បីការពារ រូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយស្ថិតក្នុងករណី ដែលពេលវេលានៃអំពើបំពាន ឬអំពើរំលោភសិទ្ធិស្ថិតជិតគ្នា និងមានតុល្យភាពរវាងវិធីការពារ និង កម្រិតនៃអំពើបំពាននោះ។ រីឯស្ថានភាពចាំបាច់ គឺសំដៅទៅលើអំពើរំលោភដែលមិនអាចជៀស វាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ឬគ្រោះថ្នាក់ដែលហៀបនឹងកើតឡើងយ៉ាងពិតប្រាកដ

[29] មាត្រា១៥ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ២០០៥។

ហើយដែលស្ថិតក្នុងករណីមាន តុល្យភាពរវាងវិធីការពារ និង កម្រិតនៃគ្រោះថ្នាក់នោះ[30]។ ដើម្បីជាការបកស្រាយស្រួលយល់នូវចំណុចនេះ ឧបមាថាមានជនវិបល្លាសស្មារតីម្នាក់បានកាន់កូនកាំបិតមួយដើមសំដៅទៅរកហ្វូងមនុស្សជាច្រើនក្នុងបំណងចាក់សម្លាប់មនុស្សទាំងនោះ។ ករណីនេះ ជាស្ថានភាពបន្ទាន់មួយដែលតម្រូវឲ្យនគរបាលសមត្ថកិច្ចសម្រេចចិត្តធ្វើការបាញ់ជនវិបល្លាសស្មារតីនោះដើម្បីចៀសវាងនូវគ្រោះថ្នាក់ដែលនឹងប៉ះទង្គិចលើមនុស្សជាច្រើនផ្សេងទៀត។

**៣.៣. ករណីប្រធានសក្តិ**

ក្នុងករណីដែលឃ្លាំងដាក់អាវុធមួយ ដែលមានអាវុធជាច្រើន រួមទាំងគ្រាប់បែកផងនោះ ស្រាប់តែពេលមានភ្លៀងធ្លាក់ខ្លាំង ហើយមានរន្ទះបាញ់ចំទៅកន្លែងដាក់អាវុធនោះធ្វើអោយផ្ទុះគ្រាប់បែក និងអាវុធផ្សេងៗឆេះរាលដាលទៅកន្លែងផ្សេងៗទៀតយ៉ាងខ្លាំង និង មនុស្សដែរនៅជិតនោះរងរបួសផងដែរ។ នេះកើតមានឡើងដោយប្រធានសក្តិ ដូច្នេះឆ្មាំឃ្លាំងពុំមានកាតព្វកិច្ចទទួលខុសត្រូវឡើយ។

**៣.៤. កំហុសជនរងគ្រោះ**

ឧទាហរណ៍ថា មានកន្លែងមួយគេកំពុងហ្វឹកហាត់បាញ់អាវុធ ស្រាប់តែមានបុរសម្នាក់រត់ចូលទៅកន្លែងគេកំពុងតែហាត់បាញ់អាវុធ ក៏បានត្រូវបានគេបាញ់បញ្ចិតត្រូវជើងខាងស្តាំរបស់បណ្តោលអោយរបួស។ ករណីគឺជាកំហុសជនរងគ្រោះទាំងស្រុងព្រោះគាត់បានរត់ចូលកន្លែងគេខ្លួនឯង។

**៣.៥. កំហុសតតិយជន**

ក្នុងករណី លោក ក បានលួចយកកាំភ្លើងរបស់លោក ខ ហើយគាត់បានយកកាំភ្លើងនោះទៅបាញ់បុគ្គលម្នាក់ទៀតដែលមានជម្លោះជាមួយគ្នាបណ្តាល ជននោះមិនស្លាប់ប៉ុន្តែមានរបួស។ វាមិនមែនជាការទទួលខុសត្រូវរបស់លោក ខ ដែលជាកម្មសិទ្ធិករទេ ប៉ុន្តែជាការទទួលខុសត្រូវរបស់លោក ក។

## កថាភាគទី២. ថ្នាំគីមីកសិកម្ម (ថ្នាំ និងជីកសិកម្ម)

វិស័យកសិកម្ម នៅកម្ពុជាត្រូវបានគេចាត់ទុកជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ហើយដោយមានការវិវត្តពីការដាំដុះតាមបែបបុរាណកម្ម ប្រែក្លាយទៅជាបែបទំនើបកម្ម មានដូចជាការប្រើប្រាស់គ្រឿងយន្ត ជាពិសេសបូកផ្សំ

[30] មាត្រា៧៥៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

និងការប្រើប្រាស់ថ្នាំ និងជីកសិកម្មគីមីផងដែរ ដើម្បីសម្រួលដល់ការដាំដុះ និងបំពេញតម្រូវការទីផ្សារសង្គម។ ទន្ទឹមនិងនេះ វាក៏បានផ្តល់នូវផលប៉ះពាល់ដែរ បើមានការប្រើប្រាស់មិនត្រឹមត្រូវ។

## ១. និយមន័យ

ថ្នាំកសិកម្ម សំដៅដល់ផលិតផលដែលលាយផ្សំដោយសមាសធាតុផ្សំសកម្មនិងសារធាតុនិចល ដែលត្រូវបានចាត់ថ្នាក់ជាក្រុមថ្នាំកសិកម្មគីមីជីវសាស្ត្រ និងត្រូវបានប្រើប្រាស់ដើម្បីបង្ក្រាបសមាសភាពចង្រៃរួមមានការបំផ្លាញ ការទាក់ទាញ ការបណ្តេញ សត្វល្អិតចង្រៃ ប្រភេទតិណជាតិគ្មានប្រយោជន៍និងធ្វើឲ្យធូរស្រាលជំងឺដំណាំដែលបង្កដោយផ្សិត បាក់តេរី ណេម៉ាតូត និងវីរុស ក្នុងគោលបំណងការពារផលដំណាំ ។ ថ្នាំកសិកម្មក៏ត្រូវបានរាប់បញ្ចូលផងដែរនូវសារធាតុគីមីកសិកម្មដែលជួយជំរុញ ឬសម្រួលដល់មុខងារ សរីរសាស្ត្ររបស់រុក្ខជាតិ ដូចជានិយ័តករការលូតលាស់ឬជំរុញការលូតលាស់របស់ដំណាំ ការជម្រះ ស្លឹក មែក ឬជាភ្នាក់ងារធ្វើឱ្យហាលនូវផ្លែឈើឬការពារការជ្រុះនូវផ្លែឈើចាស់ជិតដល់ដំណាក់កាល ទុំ ឬជាសារធាតុគីមីកសិកម្មដែលប្រើប្រាស់ចំពោះដំណាំនៅដំណាក់កាលមុន ឬក្រោយប្រមូលផល[31]។

ជីកសិកម្ម សំដៅដល់អង្គធាតុដែលប្រើប្រាស់ក្នុងដី ឬលើរុក្ខជាតិដោយផ្តល់នូវសារធាតុចិញ្ចឹមមួយ ឬច្រើន ដើម្បីជំរុញនូវបណ្តូរកម្មគីមីដែលជួយទ្រទ្រង់ និងធ្វើឱ្យប្រសើរដល់ការលូតលាស់ ឬទិន្នផលទាំងបរិមាណនិងគុណភាពនៃដំណាំ[32]។

## ២. ការទទួលខុសត្រូវ

### ២.១. ការប្រើប្រាស់សារធាតុហាមឃាត់

ការដែលប្រើប្រាស់នូវសារធាតុហាមឃាត់វាអាចប្រឈមមុខប៉ះពាល់ជាច្រើនដូចជាសុខភាពនិងបរិស្ថាន ហើយថ្នាំកសិកម្មហាមឃាត់ សំដៅដល់ថ្នាំកសិកម្មដែលត្រូវបានហាមឃាត់ចំពោះគ្រប់ការបើប្រាស់តាមរយៈប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន។ វាត្រូវបានរាប់បញ្ចូលផងដែរនូវប្រភេទថ្នាំកសិកម្មដែលត្រូវបានបដិសេធមិនឱ្យប្រើប្រាស់ដំបូង ឬថ្នាំកសិកម្មដែលបានដកហូតមកវិញពីចរាចរណ៍លើទីផ្សារក្នុងស្រុក ដោយផ្អែកតាមភស្តុតាងទិន្នន័យស្រាវជ្រាវច្បាស់លាស់បញ្ជាក់ថា ការប្រើប្រាស់ប្រភេទថ្នាំកសិកម្មនោះធ្វើឱ្យប៉ះពាល់

[31] ចំណុចទី១៣ សន្ធនានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឆ្នាំ២០១១។

[32] ចំណុចទី៨ សន្ធនានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឆ្នាំ២០១១។

យ៉ាងធ្ងន់ធ្ងរ[33]។ ប្រភេទថ្នាំកសិកម្មដែរគេហាមឃាត់ មានដូចជា អង់ដូស៊ុលហ្វាន , មេតាមីដូហ្វូស , មេទីដាចុង , មេតូមីល , មេវីនហ្វូស ។ល។

អាស្រ័យហេតុនេះ បើសិនណាជនណាម្នាក់បានប្រើប្រាស់នូវសារធាតុទាំងនោះ ហើយបណ្តាលឲ្យអ្នកដទៃមានគ្រោះថ្នាក់ប៉ះពាល់ដល់សុខភាព អាចមានជាការចេញរោគសញ្ញាភ្លាមៗនៅពេលដែលពុល ឬភាពពុលរ៉ាំរ៉ៃដោយទទួលរងផលប៉ះពាល់រាប់ខែ ជនរងគ្រោះអាចទាមទារសំណងការខូចខាតបាន ក៏ដូចជាសំណងនៃការខូចខាតនូវអនាគតដែលបានរំពឹងទុក[34]។

ស្របគ្នានេះ កំហុសការគ្រប់គ្រង និងប្រើប្រាស់ថ្នាំកសិកម្មមិនត្រឹមត្រូវតាមបច្ចេកទេស ក៏ជាចំណែកមួយនៃការបង្កឲ្យមានគ្រោះថ្នាក់ផងដែរ។

### ២.២. ការគ្រប់គ្រង និងប្រើប្រាស់ថ្នាំកសិកម្មមិនត្រឹមត្រូវតាមបច្ចេកទេស

ការប្រើប្រាស់ថ្នាំពុលមិនបានត្រឹមត្រូវ នឹងមិនត្រឹមតែបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ប៉ុណ្ណោះទេ វាថែមទាំងបង្កដល់មហន្តរាយដល់អ្នកដទៃទៀត និងធ្វើអោយហិនហោចដល់ជីវចំរុះនានាដែលមាននៅក្នុងបរិស្ថាន មានន័យថា ការប្រើប្រាស់ថ្នាំកសិកម្មមិនបានត្រឹមត្រូវ ជាការបំផ្លាញខ្លួនឯង និងអ្នកដទៃទៀត។ ការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ថ្នាំកសិកម្មគ្រប់ថ្នាំកសិកម្មទាំងអស់ គឺសុទ្ធតែពុល ប្រសិនបើយើងប្រើប្រាស់វាមិនបានសមស្រប ដូច្នេះមុននឹងប្រើប្រាស់វាសូមអនុវត្តទៅតាមការណែនាំស្តីពីការប្រុងប្រយ័ត្ន និងសុវត្ថិភាពក្នុងការប្រើប្រាស់ដែលមានប្រាប់បង្ហាញនៅលើសំបកខ្ចប់ថ្នាំទាំងនោះ។

ដោយហេតុថា បងប្អូនកសិករនៅក្នុងប្រទេសកម្ពុជា កំពុងតែមានការនិយមប្រើប្រាស់ថ្នាំកសិកម្មដើម្បីការពារដំណាំ ដោយគិតថាវាជាបច្ចេកទេសមួយទាន់សម័យ ហើយលឿនទាន់ចិត្ត ប៉ុន្តែពួកគាត់មិនទាន់យល់ដឹងឱ្យបានស៊ីជំរៅ អំពីថ្នាំកសិកម្ម និងភាពគ្រោះថ្នាក់របស់វាឱ្យបានច្បាស់លាស់នៅឡើយទេ[35]។ ជុំវិញបញ្ហានេះ មានបុគ្គលមួយចំនួនបានលាយ ថ្នាំកសិកម្មបញ្ចូលគ្នាជាច្រើនមុខ ឬច្រើនប្រភេទ ហើយច្រើនជាថ្នាំកសិកម្មដែលមានការហាមឃាត់មិនឱ្យប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងទៀតផង។ លើសពីនេះ បញ្ហាការ

[33] ចំណុចទី១៨ សន្ធនានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឆ្នាំ២០១១។
[34] មើលមាត្រា៧៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[35]សៀវភៅស្តីពីវិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ក្នុងការប្រើប្រាស់ និងការទុកដាក់ថ្នាំកសិកម្ម ឆ្នាំ២០០៣, ទំព័រ១។

ទុកដាក់សំបកថ្នាំកសិកម្មដែលប្រើហើយ ពួកគាត់មិនសូវមានការប្រុងប្រយ័ត្នលើការការពារ ឬ ឱ្យបានត្រឹមត្រូវទេ។

យើងអាចនិយាយបានថា សកម្មភាពទាំងអស់នេះជាមូលនៃការទទួលខុសត្រូវលើកំហុសនៃការប្រើប្រាស់របស់ប្រជាកសិករ ដែលមានដូចជាការប្រើប្រាស់ថ្នាំលាយដោយខ្លួនឯង ការប្រើប្រាស់ថ្នាំលើសកម្រិតក្នុងគោលបំណងឲ្យឆាប់ទទួលផល បូករួមទាំងការគ្រប់គ្រងមិនបានត្រឹមត្រូវ ទើបបណ្តាលឲ្យមានផលប៉ះពាល់ដល់អ្នកដទៃ ហើយត្រូវ ត្រូវជួសជុលការខូចខាត ឬត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន ។ បើសិនណាបុរស ក បាញ់ថ្នាំកម្ចាត់សត្វនៅចម្ការរបស់គាត់ដែរនៅជិតផ្ទះ លោក ខ ពេលនោះបុរស ក បានបាញ់ថ្នាំខ្លាំងពេកបានសាយភាយទៅផ្ទះរបស់ លោក ខ បានធ្វើអោយក្រុមគ្រួសារ លោក ខ បានពុលមានអាការៈក្អួតផង ខ្លះក៏វិលមុខដោយពុលថ្នាំកសិកម្មដែល បុរស ក បានបាញ់ភាយខ្លាំងពេក ។ ហើយបុរស ក ត្រូវតែទទួលខុសត្រូវក្នុងរឿងនេះពីព្រោះដោយសារតែការធ្វេសប្រហែលរបស់គាត់ បានបាញ់ថ្នាំសាយភាយបណ្តោលឲ្យគេពុល ។

### ៣. ការរួចផុតពីការទទួលខុសត្រូវ

#### ៣.១. កំហុសអ្នកប្រើប្រាស់

ឧទាហរណ៍ បុរស ក បានទិញជីមួយកន្លែង ដោយនៅលើសំបកជីគេបានប្រាប់ថាក្នុងមួយថ្ងៃត្រូវដាក់ជីតែមួយដងប៉ុណ្ណោះ តែដោយសារតែគាត់មិនបានមើលនៅលើសំបកជី ហើយដោយសារតែចិត្តគាត់ចង់បានផលលឿនទៀតនោះ គាត់បានដាក់ជីមួយថ្ងៃ បីដង ធ្វើអោយដំនាំរបស់គាត់ខូចខាតអស់។ វាជាកំហុសអ្នកប្រើប្រាស់ខ្លួនឯង ដែលមិនអនុវត្តតាមក្បួនខ្នាតនៃការប្រើប្រាស់ និងមិនអាចទាមទារសំណងពីអ្នកលក់ថ្នាំកសិកម្មឡើយ។

#### ៣.២. ករណីប្រធានសក្តិ

ឧទាហរណ៍ មានឃ្លាំងស្តុកទំនិញមួយមានស្តុកថ្នាំកសិកម្មធំមួយ ចៃដន្យស្រាប់តែមានគ្រោះធម្មជាតិមានភ្លៀងធ្លាក់យ៉ាងខ្លាំង បានធ្វើអោយលិចឃ្លាំងបានធ្វើអោយថ្នាំកសិកម្មបានហូរចេញមកក្រៅ ធ្វើអោយប៉ះពាល់ដល់កសិកម្មដែលនៅក្បែរខូចខាតយ៉ាងខ្លាំង។ ករណីនេះគឺមកពីគ្រោះធម្មជាតិ និងមិនអាចធ្វើការទប់ស្កាត់បាន ជាហេតុបង្កឲ្យមានការខូចខាត។

## ផ្នែកទី៤. វត្ថុទូទៅផ្សេងៗ

### កថាភាគទី១. ការទទួលខុសត្រូវលើវត្ថុទូទៅផ្សេងៗ

ចំណុច នេះ យើងមិនបានធ្វើការសិក្សាទៅ ការទទួលខុសត្រូវ លើអំពើ របស់ វត្ថុ ទូទៅ(លើកលែងសត្វ) មានដូចជា ការទទួលខុសត្រូវ លើសំណង់អគារ គ្រឿង សម្ភាង អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ថ្នាំគីមីកសិកម្ម និងការទទួលខុសត្រូវលើអំពើរបស់សត្វនោះទេ។ ប៉ុន្តែយើងនឹងធ្វើការសិក្សា បកស្រាយ ជាគោលការណ៍បន្ថែម ពីលើចំណុចទាំងអស់នោះ ដែលក្នុងនោះមានដូចជាលើកឡើងអំពីអំពើនៃវត្ថុ រួមទាំងសម្ភារៈប្រើប្រាស់ទូទៅផ្សេងៗ ដោយមានលក្ខខណ្ឌចំនួន៣គឺវត្តមាននៃវត្ថុ បុគ្គលដែលមានកាតព្វកិច្ចថែរក្សាវត្ថុ និងការចូលរួមរបស់វត្ថុ។

## ១. វត្តមាននៃវត្ថុ

វត្ថុជាចលនវត្ថុ ហើយចលនវត្ថុនោះវាអាចមានម៉ាស៊ីនរឺគ្មានម៉ាស៊ីនឧបករណ៍ផ្សេងៗ ហើយវត្ថុខ្លះវាគ្មានគ្រោះថ្នាក់ទេដូចជា តុ ទូ កៅអី កង់ ប៉ុន្តែវត្ថុដែលគ្មានគ្រោះថ្នាក់នោះវាអាចក្លាយជាវត្ថុដែលមានគ្រោះថ្នាក់បានបើសិនណាជាកម្មសិទ្ធិករឬអ្នកគ្រប់គ្រងវត្ថុនោះយកវាទៅទុកនៅកន្លែងដែលមិនគួរដាក់ឬទុកឬ ទុកដាក់ត្រឹមត្រូវ ហើយប៉ុន្តែវាស្ថិតក្នុងស្ថានភាពមួយដែលជនរងគ្រោះមិនអាចមើលឃើញអំពីភាពគ្រោះថ្នាក់[36]។

ឧទាហរណ៍ : លោក ក បានចតកង់ដាក់កណ្តាលផ្លូវនៅពេលយប់ងងឹតបណ្តាលឲ្យអ្នកដំណើរជាបុកធ្វើឱ្យមានគ្រោះថ្នាក់។ ឬ រថយន្តដែលខូចខាតហើយចតចោលនៅផ្លូវហើយពេលយប់ងងឹតបើសិនណាជាមិនបានដាក់ភ្លើងសញ្ញាភ្លើង រឺ មែកឈើដើម្បីបង្ហាញនោះ កាលណាមានព្យសនកម្មកើតឡើង គឺ មានការទទួលខុសត្រូវ ប៉ុន្តែប្រសិនបើបានដាក់ចំណាំរឺបង្ហាញត្រឹមត្រូវហើយនៅតែមានការខូចខាតកើតឡើង នោះវាជាកំហុសជនរងគ្រោះ។

នេះបញ្ជាក់បានថា សម្ភារៈប្រើប្រាស់ផ្សេងៗក៏អាចជាវត្ថុដែលអាចបង្កជាគ្រោះថ្នាក់បានដែរបើសិនជាយើងទុកដាក់មិនត្រឹមត្រូវ។ ពេលខ្លះវត្ថុផ្សេងៗ ដែលគិតថាមិនសំខាន់ក៏វាអាចបង្កជាគ្រោះថ្នាក់កើតឡើងបានដែរ ហេតុនេះរបស់ប្រើប្រាស់ត្រូវទុកដាក់អោយបានត្រឹមត្រូវមិនត្រូវធ្វេសប្រហែសឡើយ ដើម្បីកុំអោយមានរឿងកើតឡើងដោយមិនដឹងខ្លួន។

## ២. បុគ្គលដែលមានកាតព្វកិច្ចថែរក្សាវត្ថុ

បុគ្គលដែលមានសិទ្ធិថែរក្សាវត្ថុ ត្រូវចាត់ទុកថាជា កម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិថែរក្សាវត្ថុ ចំពោះបុគ្គល ទាំងឡាយណាដែលជាអ្នកមើលថែរក្សា គ្រប់គ្រង ឬកំពុងប្រើប្រាស់វត្ថុនោះ ហើយត្រូវសន្មតថាត្រូវទទួលខុសត្រូវលើអំពើនៃវត្ថុ បើសិនណាជាមានព្យសនកម្មកើតចេញពីវត្ថុ លើកលែងតែមានភស្តុតាងផ្សេងមកបញ្ជាក់

[36] ញឹក វុធ្ធី, នីតិកាតព្វកិច្ច២ (២០២១)។

ថាខ្លួនគ្មានកំហុស។ ត្រង់ចំណុចនេះ មានន័យថាលុះត្រាតែអំពើដែលកើតចេញពីវត្ថុដែលមានម្ចាស់គ្រប់គ្រង ទើបមានការទទួលខុសត្រូវ ហើយក៏មានករណីដែលជាមូលហេតុនាំឲ្យរួចផុតពីការទទួលខុសត្រូវបានផងដែរ។

## ៣. ការចូលរួមរបស់វត្ថុ

ការចូលរួមរបស់វត្ថុ មានន័យថាក្នុងពេលមានព្យសនកម្ម ត្រូវមានទំនាក់ទំនងពីហេតុទៅផលនៃការចូលរួមរបស់វត្ថុនិងព្យសនកម្ម ពោលគឺការខូចខាតកើតចេញពីការចូលរួមរបស់វត្ថុ ប៉ះទង្គិចជាសម្ភារៈជាមួយភាគីដែលរងគ្រោះដោយវត្ថុបានប៉ះទង្គិចទៅលើភាគីជនរងគ្រោះរឺភាគីរងគ្រោះត្រូវបានប៉ះទង្គិចដោយវត្ថុ ជាហេតុធ្វើឲ្យមានការខូចខាតកើតឡើង[37]។

ឧទាហរណ៍៖ បុរស ក បានយកចង្ក្រានហ្គាសតូចមកជៀនត្រីនៅមុខផ្ទះ ពេលដែលកំពុងជៀនត្រីនៅមុខផ្ទះក៏ស្រាប់តែអស់ហ្គាសគាត់ក៏បានដើរទៅយកកំប៉ុងមកប្តូរ ពេលនោះគាត់កាន់កំប៉ុងហ្គាសមកចំនួន២ ដើម្បីផ្លាស់ប្តូរ មួយគាត់បានយកទៅដាក់ក្នុងចង្ក្រានមួយទៀតគាត់ក៏បានដាក់នៅលើតុដើម្បីសាគួរ។ពេលដែលគាត់ជៀនត្រីរួចគាត់ក៏បានប្រមូលរបស់របរចង្ក្រានចូលទៅក្នុងផ្ទះ តែគាត់ក៏បានភ្លេចកំប៉ុងហ្គាសមួយទៀតទុកចោលនៅលើតុ កំប៉ុងហ្គាសក៏បានទុកចោលហាលក្តៅយូរម៉ោងស្រាប់តែផ្ទុះខ្ទាតចំបុរស ខ ដែលជាអ្នកជិតផ្ទះរបស់បុរស ក ដែលគាត់កំពុងឈរលេងនៅមុខផ្ទះធ្វើអោយបុរស ខ មានរបួសដោយសារខ្ទាតកំប៉ុងហ្គាសដែលផ្ទុះខ្ទាតចំមកប៉ះគាត់។

ករណីខ្លះមិនមែនជាការប៉ះពាល់ជាសម្ភារៈនៃវត្ថុជាមួយជនរងគ្រោះ ប៉ុន្តែវាមានការចូលរួមរបស់វត្ថុជាមួយនឹងមុខងារដែលបង្កឡើងពីវត្ថុហើយករណីនេះកម្មសិទ្ធិត្រូវទទួលខុសត្រូវ[38]។

ដូចក្នុងករណីរថយន្ត របស់លោក ក បានចតនៅលើផ្លូវហើយដោយខ្វះការប្រុងប្រយ័ត្នមិនមើលឆ្វេងស្តាំមុខក្រោយហើយបើកទ្វារឡានស្របពេលនោះលោក ខ ជិះម៉ូតូទៅដល់ក៏បានចាប់ប្រាំងយ៉ាងខ្លាំងដើម្បីបញ្ចៀសការបុកទង្គិចហើយបណ្តាលឲ្យគាត់ដួល។ ករណីនេះគ្មានការប៉ះពាល់ជាមួយសំភារៈនៃវត្ថុជាមួយជនរងគ្រោះទេ ហើយការដួលដោយខ្លួនឯងនេះដោយសារដែលទ្វារឡានដែលបើកភ្លាមៗនោះ ហើយវាមានការចូលរួមរបស់វត្ថុជាមួយនឹងមុខងារដែលបង្កឡើងពីវត្ថុ។

## កថាភាគទី២. មូលហេតុនាំឲ្យរួចផុតពីការទទួលខុសត្រូវ

[37] ញឹក វុទ្ធី, នីតិកាតព្វកិច្ច២ (២០២១)។
[38] ញឹក វុទ្ធី, នីតិកាតព្វកិច្ច២ (២០២១)។

**១. ករណីប្រធានសក្តិ**

ឧទាហរណ៍ថា មានដើមត្នោតជាច្រើននៅក្នុងផ្ទះរបស់ ក ថ្ងៃមួយក៏មានខ្យាល់យ៉ាងខ្លាំងព្រមទាំងមានភ្លៀងធ្លាក់ស្រាប់តែពេលនោះក៏មានរន្ទះបាញ់បានបាញ់ចំដើមត្នោត បណ្តាលអោយបានបាក់រលំទៅចំពីខាងមុខផ្ទះរបស់ ខ ធ្វើអោយខូចខាតពីខាងមុខផ្ទះរបស់ ខ នេះគឺមកពីគ្រោះធម្មជាតិ ដូច្នេះ ក រួចផុតពីការទទួលខុសត្រូវ ។

**២. តតិយជន**

បុរស ក បានខ្ចីម៉ូតូរបស់ ខ ជិះទៅទិញម្ហូបស្រាប់តែបុរស ខ ជិះបានដល់ពាក់កណ្តាលផ្លូវស្រាប់តែបានបុកក្មេងម្នាក់ តែបុរស ខ មិនបានដួលទេហើយក៏មិនបានឈប់មើល គាត់ក៏បានជិះរត់ដែរ តែឪពុករបស់ក្មេងនោះបានឃើញផ្លាកលេខ គាត់ក៏បានអោយប៉ូលីសតាមរកហើយក៏ដឹងថាម៉ូតូនោះគឺជារបស់ ក ។ ក្នុងករណីនេះបុរស ក រួចផុតពីការទទួលខុសត្រូវទោះគាត់ជាម្ចាស់ម៉ូតូក៏ដោយ ពីព្រោះគាត់មិនបានជិះ តែបុរស ខ ទេដែលជាអ្នកខ្ចីម៉ូតូជិះទៅបុកក្មេងនោះ។

**៣. កំហុសជនរងគ្រោះ**

ប្រសិនបើយើងសង្កេតមើលការធ្វើលើដងផ្លូវ មានបុគ្គលមួយចំនួនបើកបរបើកបរមិនគោរពតាមច្បាប់ចរាចរណ៍ ឧទាហរណ៍មានក្មេងប្រុសម្នាក់បានបើកម៉ូតូលើសល្បឿនកំណត់ រួចក៏ជ្រុលទៅបុករថយន្តដែលកំពុងធ្វើដំណើរបញ្រ្ចាសទិសគ្នាក្នុងល្បឿនយឺត ដែលបណ្តាលឲ្យមានរបួសជាទម្ងន់។ ករណីនេះ ជាកំហុសរបស់ជនរងគ្រោះ ព្រោះការខូចខាតកើតឡើងពីអំពើរបស់ខ្លួនឯង។

# ជំពូកទី ៣

# ការទទួលខុសត្រូវលើអំពើរបស់សត្វ

# ជំពូកទី ៣

# ការទទួលខុសត្រូវលើអំពើរបស់សត្វ

## ផ្នែកទី១. អំពីសត្វ និងអ្នកកាន់កាប់សត្វ

### កថាភាគទី១. ប្រភេទនៃសត្វ និងការទទួលខុសត្រូវ

ទ្រព្យរបស់មនុស្សមានច្រើនប្រភេទ ក្នុងនោះសត្វ ក៏ត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិផងដែរ។ តាមប្រព័ន្ធច្បាប់របស់យើងបានកំណត់ថា សត្វជាវត្ថុមានជីវិត ដោយហេតុថាសត្វក៏ចេះមានអារម្មណ៍ឈឺចាប់ រីករាយ ទុក្ខព្រួយ និងការភ័យខ្លាចជាដើម។ ម្យ៉ាងវិញទៀត មិនខុសគ្នាពីតុ ទូ កៅអី ឬសម្ភារៈផ្សេងៗ សត្វត្រូវបានគ្រប់គ្រង រួមទាំងមានការទទួលខុសត្រូវដោយម្ចាស់។

សត្វត្រូវបានបែងចែកជាពីរប្រភេទគឺ សត្វព្រៃ និងក្នុងស្រុក។ រីឯ ការទទួលខុសត្រូវលើអំពើរបស់សត្វអាចកើតមាន លុះត្រាតែសត្វនោះមានម្ចាស់និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ សត្វ ដែលមានម្ចាស់អាចជាសត្វស្រុក ឬសត្វព្រៃផ្សាំង អាចជាការយកជ្រូកព្រៃ ឬយកដំរីមកចិញ្ចឹមជាដើម។

### ១. សត្វព្រៃ

សត្វព្រៃ គឺជាសត្វដែលរស់នៅក្នុងព្រៃ ឬក្នុងតំបន់ជុំវិញដោយធម្មជាតិ ។ នេះមានន័យថា ពួកវារស់នៅដោយខ្លួនឯងដោយគ្មានការមើលថៃពីមនុស្សដោយស្វែងរកអាហារ ទីជម្រក ទឹក និងតម្រូវការផ្សេងទៀតរបស់វាដោយខ្លួនឯងនៅក្នុងជម្រកធម្មជាតិជាក់លាក់មួយ។ ទោះជាបែបនេះក្តី មិនមែនមានន័យថាច្បាប់ពុំមានចែងពីបទបញ្ញត្តិផ្សេងៗក្នុងការគ្រប់គ្រងពួកវាឡើយ។ ជាក់ស្តែង ពពួកសត្វព្រៃទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាទ្រព្យសម្បត្តិរបស់រដ្ឋ និងស្ថិតក្រោមការការពារថែមទៀតផង[39]។

យ៉ាងណាមិញ មិនមានកាតព្វកិច្ចទទួលខុសត្រូវសម្រាប់បុគ្គលណាម្នាក់ឡើយ ទៅលើទង្វើបង្កការខូចខាតរបស់សត្វព្រៃនោះទេ។ មូលហេតុថា សត្វក្នុងព្រៃជាសម្បត្តិរបស់រដ្ឋក៏ពិតមែន ប៉ុន្តែពួកវារស់នៅក្នុងព្រៃដោយខ្លួនឯងទើបគេចាត់ទុកថាពួកវាគ្មានម្ចាស់ទេ ដូច្នេះបើមានព្យសនកម្មកើតឡើងពេល គឺគ្មានអ្នកទទួល

[39] មើលមាត្រា៤៨ ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២។

ខុសត្រូវទេ។ ប៉ុន្តែ ក្នុងករណីដែលសត្វព្រៃត្រូវបានគេយកទៅចិញ្ចឹម ឬផ្សាំ ពួកវាក្លាយទៅជាចិញ្ចឹមដែលមានម្ចាស់គ្រប់គ្រង ហេតុនេះបណ្ដាលអោយមានការទទួលខុសត្រូវ។

ឧទាហរណ៍ ៖ ក្រុមអភិរក្សសត្វព្រៃមួយក្រុមបានជួយសង្គ្រោះ កូនសត្វដំរីមួយក្បាលពីអន្ទាក់ព្រានព្រៃ និងបានយកវាទៅចិញ្ចឹម ឬផ្សាំអោយរស់នៅជាមួយមនុស្ស។ ថ្ងៃមួយវាបានទៅស៊ី និងបំផ្លាញដំណាំរបស់អ្នកភូមិអស់យ៉ាងច្រើន ហេតុនេះម្ចាស់ដំរី គឺជាអ្នកមានកាតព្វកិច្ចសងសំណងការខូចខាតដល់អ្នកភូមិ។

## ២. សត្វស្រុក

សត្វក្នុងស្រុក គឺជាសត្វដែលត្រូវបានជ្រើសរើសបង្កាត់ពូជ និងសម្របតាមហ្សែនជាច្រើនជំនាន់ ដើម្បីរស់នៅជាមួយមនុស្ស។ សត្វពាហនៈ ដែលជាធម្មតាគ្មានគ្រោះថ្នាក់ដល់មនុស្ស ត្រូវបានចាត់ថ្នាក់ជាសត្វក្នុងស្រុកផងដែរ។ រាល់ព្យសនកម្មដែលបង្កឡើងដោយសត្វក្នុងស្រុក គឺត្រូវមានការទទួលខុសត្រូវ ព្រោះជាទូទៅសត្វទាំងអស់នោះតែងមានអ្នកថែរក្សា។ នេះមានន័យថា ម្ចាស់សត្វនិងទទួលខុសត្រូវ ប្រសិនបើសត្វរបស់ខ្លួនធ្វើឱ្យនរណាម្នាក់រងរបួស ឬបំផ្លាញទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ប៉ុន្តែការទទួលខុសត្រូវ និងមិនអាចកើតមានទេក្នុងករណីដែលសត្វស្រុកទាំងអស់នោះជាសត្វអានាថា។ ដូច្នេះ ជនរងគ្រោះពុំអាចធ្វើបណ្ដឹងទាមទារសំណងបានទេ។

# កថាភាគទី២. អំពីអ្នកកាន់កាប់សត្វ

## ១. និយមន័យ

អ្នកកាន់កាប់សត្វ សំដៅលើជនជាកម្មសិទ្ធិករ ឬហៅម្យ៉ាងទៀតថាជាឆ្មាំសត្វដែលជាបុគ្គលមានករណីកិច្ច ចិញ្ចឹម ថែរក្សា គ្រប់គ្រង និងការពារសត្វចញ្ចឹមណាមួយ របស់ខ្លួន ដោយបុគ្គលដែលរក្សាសត្វនោះ ត្រូវមានកាតព្វកិច្ចថែទាំតាមផ្លូវច្បាប់ ដើម្បីការពារកុំឱ្យបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

## ២. លក្ខណៈសម្បត្តិរបស់អ្នកកាន់កាប់សត្វ

លក្ខណៈសម្បត្តិរបស់អ្នកកាន់កាប់សត្វ គឺមានលក្ខណៈនៃការគ្រប់គ្រង ប្រើប្រាស់ ការចាត់ចែង ដឹកនាំសត្វ និងការត្រួតពិនិត្យសត្វ។ ហេតុនេះ ប្រសិនបើបុគ្គលណាម្នាក់ជាអ្នកកាន់កាប់សត្វ ជននោះជាកម្មសិទ្ធិករនៃសត្វចិញ្ចឹមរបស់ខ្លួន ដែលអាចជាមេគ្រួសារ ឬជាសមាជិកគ្រួសារដែលជាអនីតិជន ឬអាចជាជនដែលមិនមែន

ជាម្ចាស់។ ជារួម លក្ខណៈសម្បត្តិរបស់អ្នកកាន់កាប់សត្វត្រូវបានបែងចែកជាពីរប្រភេទគឺៈ អ្នកកាន់កាប់សត្វជាកម្មសិទ្ធិករ និងអ្នកកាន់កាប់សត្វមិនមែនជាកម្មសិទ្ធិករ។

**២.១. អ្នកកាន់កាប់សត្វជាកម្មសិទ្ធិករ**

អ្នកកាន់កាប់សត្វជាកម្មសិទ្ធិករ គឺជាបុគ្គលដែលមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង ប្រើប្រាស់ ការចាត់ចែង ដឹកនាំ និងការត្រួតពិនិត្យសត្វ ហើយសន្មតថាជាឆ្នាំដែលមានទំនួលខុសត្រូវលើអំពើរបស់សត្វ។ នេះបានន័យថា បើសត្វនោះកំពុងស្ថិតនៅក្រោមកាគ្រប់គ្រង មើលថែរបស់ម្ចាស់វា នោះម្ចាស់ត្រូវបានសន្មតថាជាកម្មសិទ្ធិករ។

ឧទាហរណ៍ៈ លោកឈ្មោះ ក បានទៅទិញសត្វឆ្កែមួយក្បាលពីកន្លែងលក់សត្វចិញ្ចឹម។ ល្ងាចថ្ងៃមួយគាត់បានបណ្ដើរឆ្កែរបស់គាត់ដើរតាមផ្លូវ ស្រាប់តែវាបានស្ទុះទៅខាំក្មេងស្រីម្នាក់ដែលកំពុងដើរតាមផ្លូវដែរនោះ បណ្ដាលឱ្យនាងមានរបួសចេញឈាមយ៉ាងច្រើន។ ដូចនេះ លោក ក ជាកម្មសិទ្ធិករនៃសត្វ ដែលមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង ហើយពុំអាចរួចផុតពីការទទួលខុសត្រូវលើអំពើរបស់ឆ្កែបានឡើយ។

**២.២. អ្នកកាន់កាប់សត្វមិនមែនជាកម្មសិទ្ធិករ**

អ្នកកាន់កាប់សត្វមិនមែនជាកម្មសិទ្ធិករ គឺជាបុគ្គលដែលមានសិទ្ធិមិនពេញលេញក្នុងការគ្រប់គ្រង ប្រើប្រាស់ ការចាត់ចែង ដឹកនាំ និងការត្រួតពិនិត្យសត្វ ប៉ុន្តែនៅតែត្រូវបានសន្មតថាជាឆ្នាំដែលមានទំនួលខុសត្រូវលើអំពើរបស់សត្វ មានន័យថា ក្នុងករណីដែលសត្វស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្សេងដែលមិនមែនជាម្ចាស់នោះជាអ្នកកាន់កាប់មិនមែនជាកម្មសិទ្ធិករទេ។

ឧទាហរណ៍ ៖ លោក ក បានយកសត្វឆ្កែរបស់គាត់ទៅផ្ញើនៅហាងមើលថែទាំសត្វមួយកន្លែងរបស់លោក ខ ដោយហេតុថាគាត់ត្រូវចុះធ្វើការតាមខេត្តមិនអាចយកវាទៅតាមជាមួយបាន។ នេះបង្ហាញថា សត្វឆ្កែនោះគឺបានឋិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលមិនមែនជាម្ចាស់ដែលជាកម្មសិទ្ធិករទេ។ ក្នុងករណីដែលវាបង្កឱ្យមានរបួសស្នាម ឬការខូចខាតផ្សេងៗដល់ជនរងគ្រោះណាម្នាក់ក្នុងអំឡុងពេលមើលថែទាំ នោះអ្នកកាន់កាប់ដែលមិនមែនជាកម្មសិទ្ធិករត្រូវទទួលរ៉ាប់រងសំណង មិនមែនលោក ក ដែលជាអ្នកកាន់កាប់សត្វមជាកម្មសិទ្ធិករទេ។

ជារួមមក បើសិនណាជាសត្វនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកកាន់កាប់ឬឆ្នាំមួយណា បុគ្គលនោះជាអ្នកទទួលខុសត្រូវលើអំពើរបស់សត្វ។

# ផ្នែកទី០២ ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

## កថាភាគទី១. លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

ជាទូទៅ ប្រសិនបើអ្នកជាម្ចាស់ ឬអ្នកកំពុងថែទាំសត្វ អ្នកត្រូវតែទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលបណ្តាលដោយសត្វ។ ទោះបីជា អ្នកមានការប្រុងប្រយ័ត្ន ដូចជាការបង្ហោះសញ្ញាព្រមានថាសត្វរបស់អ្នកមានគ្រោះថ្នាក់ ឬប្រើវិធីណាផ្សេងក៏ដោយ អ្នកនៅតែទទួលខុសត្រូវក្នុងនាមជាម្ចាស់ ឬជាអ្នកថែរក្សាសត្វ។ យ៉ាងណាមិញ ក៏មានករណីមួយចំនួនដែលនាំឱ្យរួចផុតពីការទទួលខុសត្រូវលើអំពើរបស់សត្វផងដែរ។

យោងតាមមាត្រា ៧៥០ នៃក្រមរដ្ឋប្បវេណី មិនបានបង្ហាញពីកំហុស (ចេតនា ឬអចេតនា) របស់អ្នកកាន់កាប់សត្វនោះទេ ដូចនេះអ្នកកាន់កាប់សត្វត្រូវទទួលខុសត្រូវក្នុងការសងការខូតខាត ប្រសិនបើមានទោះជានៅពេលដែលអ្នកកាន់កាប់នោះបានបង្ហាញថាខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវនិងគ្មានកំហុសក៏ដោយ ។ ចំពោះលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អ្នកកាន់កាប់នេះទៀតសោត គឺត្រូវតែជាអ្នកកាន់កាប់សត្វដែលបានបណ្តាលឲ្យមានការខូចខាតដល់អ្នកដទៃ ព្រមទាំងទំនាក់ទំនងរវាងហេតុ និងផលជាចាំបាច់ ទើបអាចនាំឲ្យមានការទទួលខុសត្រូវ។

### ១. ការចូលរួមសកម្មពីសត្វ

តាមច្បាប់ពុំមានបង្ហាញថាត្រូវមានការចូលរួមសកម្មភាពពីអ្នកកាន់កាប់សត្វ ទើបមានការទទួលខុសត្រូវទេ[40]។ ហេតុនេះ រាល់អំពើ ឬសកម្មភាពផ្សេងៗរបស់សត្វផ្ទាល់ដែលនាំឲ្យមានព្យសនកម្មកើតឡើង ពោលគឺរាល់ការខូចខាត ឬបាត់បង់ណាមួយរបស់ជនរងគ្រោះ នោះជនរងគ្រោះអាចទាមទារសំណងបានដោយបញ្ជាក់ពីការចូលរួមរបស់សត្វ។ ឧបមាថា ឆ្កែរបស់លោក ក រត់លេងឆ្លងកាត់ផ្លូវនាំឲ្យមានគ្រោះថ្នាក់កើតឡើង ដោយក្មេងប្រុសម្នាក់ជិះម៉ូតូបុកនិងបង្កឱ្យមានព្យសនកម្មដែលមានការចូលរួមសកម្មពីសត្វ ហើយម្ចាស់សត្វ ឬអ្នកកាន់កាប់សត្វមិនមែនជាកម្មសិទ្ធិករត្រូវតែទទួលខុសត្រូវ។

### ២. ទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម

ដើម្បីកំណត់ថាសត្វបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ គេត្រូវធ្វើការសិក្សាទៅលើទំនាក់ទំនងរវាងអំពើ និងព្យសនៈកម្ម។ វាជាចំណងទាក់ទងទៅនិងហេតុផលរវាងអំពើរបស់សត្វ និងព្យសនកម្មដោយត្រូវ

[40]មើលមាត្រា៧៥០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

មានការប៉ះទង្គិចជាសម្ភារៈ រវាងសត្វជាមួយជនរងគ្រោះ[41]។ មានន័យថាការខូតខាត នោះគឺកើតចេញពីអំពើរបស់សត្វហើយវាបណ្ដាលឲ្យមានការខូតខាតដោយផ្ទាល់ទៅលើជនដែលរងគ្រោះ ហើយជនរងគ្រោះនោះត្រូវបង្ហាញអំពីទំនាក់ទំនងអំពើ ដែលសត្វបានប្រព្រឹត្តយ៉ាងសកម្មជាមួយនិងព្យសនកម្មឱ្យបានច្បាស់ ក្នុងការទាមទារសំណងពីអ្នកកាន់កាប់សត្វ។

ឧបមាថា សត្វក្របីមួយដើរឆ្លងកាត់ផ្លូវស្រាប់តែឡានបុកបណ្ដាលឲ្យមានការខូចខាតកើតឡើងដោយវាមានការចូលរួមសកម្មពីសត្វ នោះគឺជាការប៉ះទង្គិចជាសំភារៈរវាងសត្វជាមួយជនរងគ្រោះ ដោយកើតចេញពីអំពើរបស់ក្របីនោះ ទើបបណ្ដាលអោយមានព្យសនកម្មហើយម្ចាស់សត្វត្រូវទទួលខុសត្រូវ។ ប៉ុន្តែ ក្នុងករណីដោយឧបមាថាសត្វក្របីមួយកំពុងតែដេកនៅលើផ្លូវស្រាប់តែមានឡានមួយជិះបុកក្របីនោះតែម្តង រឺក្នុងករណីដែលម៉ូតូមួយរអិលដួលដោយផ្លូវរអិលពេកហើយខ្ទាតទៅប៉ះក្របីដែលកំពុងដេកនៅលើផ្លូវនោះ។ ករណីទាំងពីរនេះគឺពុំមានការចូលរួមពីសត្វទេ ពោលគឺគ្មានការប៉ះទង្គិចជាសំភារៈរវាងសត្វជាមួយជនរងគ្រោះឡើយដោយសត្វអកម្ម នោះម្ចាស់សត្វរួចផុតពីការទទួលខុសត្រូវ។

ចំណងទាក់ទងហេតុផលរវាងអំពើសត្វនិងព្យសនកម្មមិនពិតប្រាកដហើយផ្ទាល់ធ្វើឲ្យឆ្នាំសត្វរួចផុតពីការទទួលខុសត្រូវ។

## កថាភាគទី២. ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

លក្ខខណ្ឌ ដែលអ្នកកាន់កាប់សត្វអាចជៀសវាងការទទួលខុសត្រូវដោយផ្នែក ឬទាំងស្រុងបានគឺប្រសិនបើអាចបញ្ជាក់ថាការខូចខាតត្រូវបានបង្កឡើងដោយមូលហេតុមួយក្នុងចំណោមហេតុផលទាំងនេះដែលទាក់ទងនិងភាពគ្មានកំហុសរបស់អ្នកកាន់កាប់សត្វមានដូចជា ក្នុងករណីប្រធានសក្តិ កំហុសរបស់ជនរងគ្រោះ និងអំពើរបស់តតិយជន។

### ១. ករណីប្រធានសក្តិ

ករណីប្រធានសក្តិ ជាព្រឹត្តការណ៍ដែលកើតឡើងដោយមិនដឹងមុន ឬមិនអាចទាយទុកមុន និងទប់ស្កាត់មិនបានដោយហួសពីការគ្រប់គ្រងរបស់មនុស្ស។ រាល់ការខូតខាត ដែលកើតចេញពីអំពើ ឬការចូលរួមសកម្មរបស់សត្វដោយក្នុងករណីប្រធានសក្តិ នោះអ្នកកាន់កាប់សត្វមិនមានទទួលខុសត្រូវលើព្យសនកម្មនោះឡើយ។ ឧទាហរណ៍ថា លោក ក កំពុងបណ្តើរគោរបស់គាត់ឆ្លងកាត់ផ្លូវកំពុងមានភ្លៀងធ្លាក់ស្រាប់តែមានរន្ទះ

[41] ញឹក វុឌ្ឍី, នីតិកាតព្វកិច្ច២ (២០២១)។

បាញ់នៅក្បែរនោះបណ្ដាលឲ្យគោនោះភ័យរត់ទៅជាន់អ្នកជិះម៉ូតូក្បែរនោះ។ ឬក៏ ម្ចាស់គោបាននាំគោទៅចូលក្រោលដែលមានដំបូលនិងរនាំងបិទជិតត្រឹមត្រូវអស់ហើយប៉ុន្តែយប់នោះមានខ្យល់ព្យុះខ្លាំងបណ្ដាលឲ្យក្រោលគោបើងខ្ទេចហើយគោផ្អើលរត់ទៅជាន់របស់របរគេខូចអស់។ ប៉ុន្តែ ក្នុងករណីដែលចាំទាល់តែចប់ព្រឹត្តការណ៍ ឬករណីប្រធានសក្តិចប់សព្វគ្រប់ហើយសត្វនោះបានបង្កការខូចខាតស្វែងរកសត្វយកមកវិញគេមិនរាប់បញ្ចូលជាករណីប្រធានសក្តិទេដូច្នេះឆ្នាំសត្វត្រូវទទទួលខុសត្រូវ។

## ២. តតិយជន

តតិយជន ជាជនទី៣ដែលមិនមែនជាជនរងគ្រោះ ហើយក៏មិនមែនជាចារីនៃអំពើ។ ក្នុងករណីអំពើរបស់តតិយជនគឺទាល់តែមានលក្ខណៈជាប្រធានសក្តិ[42]។ វាមិនមែនជាប្រធានសក្តិទេ គឺវាគ្រាន់តែមានលក្ខណៈជាប្រធានសក្តិ ដែលកើតឡើងដោយមិនដឹងមុន ឬមិនអាចទាយទុកមុន និងទប់ស្កាត់មិនបានហើយឆ្នាំសត្វមិនទទួលខុសត្រូវ។ ដូចក្នុងករណីដែល បុរសម្នាក់កំពុងបណ្ដើរឆ្កែរបស់គាត់នៅតាមផ្លូវ ស្រាប់តែសុខៗមានក្មេងប្រុសម្នាក់មកពញ្ញាក់ឆ្កែរបស់គាត់លេង ហើយវាភ័យស្ទុះទៅខាំក្មេងស្រីម្នាក់ទៀតនៅក្បែរនោះ។ ការខូតខាតនេះជាមូលហេតុតតិយជន វាបានកើតឡើងភ្លាមៗដែលធ្វើឱ្យគាត់មិនអាចគ្រប់គ្រងសត្វរបស់គាត់បាន។

## ៣. កំហុសជនរងគ្រោះ

កំហុសជនរងគ្រោះ គឺការខូចខាតបណ្ដាលមកពីជនរងគ្រោះទាំងស្រុង។ មានន័យថា ជនរងគ្រោះអាចត្រូវបានរកឃើញថាមានកំហុស ប្រសិនបើជននោះមិនមានការប្រុងប្រយ័ត្នជាចាំបាច់ នៅពេលមានទំនាក់ទំនងជាមួយសត្វដែលមិនអាចស្មានទុកជាមុនបាន ដោយការបង្កហេតុដោយអំពើរបស់ខ្លួនទៅលើសត្វ។ ជាក់ស្ដែង ក្នុងករណីដែលឃើញឆ្កែកំពុងតែដេក ហើយជិះទៅបុកឆ្កែដោយចេតនាបន្ទាប់មកបណ្ដាលឲ្យមានការខូចខាតដល់ខ្លួនឯង ម្ចាស់ឆ្កែមិនទទួលខុសត្រូវដាច់ខាតពីព្រោះថាពុំមានចំណងទាក់ទងហេតុផលរវាងអំពើរបស់សត្វជាមួយនិងព្យសនកម្មពិតប្រាកដ ហើយកើតផ្ទាល់ពីទង្វើរបស់សត្វឡើយ ប៉ុន្តែវាជាកំហុសរបស់ជនរងគ្រោះទាំងស្រុង។

[42] ញឹក វុឌ្ឍី, នីតិកាតព្វកិច្ច២ (២០២១)។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនិងឆ្លងតាមការបកស្រាយលើប្រធានបទ "ការទទួលខុសត្រូវលើអំពើនៃវត្ថុ" រួចមក យើងសង្កេតឃើញថាវាមានលក្ខណៈសមស្របទៅនិងបរិបទក្នុងសង្គមបច្ចុប្បន្ន ដោយហេតុថារាល់អំពើអនីត្យានុកូលដែលបានធ្វើការសិក្សាខាងលើ ទាក់ទងទៅនិងបញ្ហាទូទៅប្រចាំដែលមិនត្រឹមតែប្រជាជននៃប្រទេសកម្ពុជាយើង កំពុងជួបប្រទះប៉ុណ្ណោះទ បណ្តាប្រទេសផ្សេងៗទៀតក៏ដូច្នោះដែរ។ សរបញ្ជាក់ឱ្យឃើញថា ប្រមុខរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំជាតិគ្រប់ជាន់ថ្នាក់បានគិតគូរយ៉ាងល្អិតល្អន់បំផុតសម្រាប់ការរស់នៅប្រាស្រ័យទាក់ទងគ្នារបស់ប្រជាជន ដោយបញ្ញត្តិច្បាប់គ្រប់គ្រងទៅលើទំនាក់ទំនងទងរដ្ឋប្បវេណីតាមកិច្ចសន្យា រួមទាំងក្រៅកិច្ចសន្យាផងដែរ។ ហេតុនេះ ប្រធានបទខាងលើគឺពិតជាបានផ្តល់សារៈសំខាន់ណាស់ ក្នុងការផ្តល់និងបង្កើននូវចំណេះដឹងថ្មីបន្ថែម ទាក់ទងនិងកាតព្វកិច្ចអនីត្យានុកូលសម្រាប់សិស្សនិស្សិតជំនាន់ក្រោយៗ អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ មិត្តអ្នកអាន ក៏ដូចជាសាធារណជនទូទៅទៀតផង។

ជាការពិតណាស់ ពុំមានបុគ្គលណាម្នាក់ចង់បង្កជម្លោះ និងធ្វើឱ្យមានការខូចខាតដល់អ្នកដទៃឡើយ ប៉ុន្តែវានៅតែអាចកើតឡើងបាន និងឈានទៅរកការទទួលខុសត្រូវបើទោះបីជាអំពើនោះមិនមែនជាកំហុសផ្ទាល់របស់ចារីក៏ដោយ។ ជាក់ស្តែង ប្រធានបទមួយនេះវាជាការទទួលខុសត្រូវលើអំពើនីត្យានុកូលរបស់កម្មសិទ្ធិករចំពោះទ្រព្យសម្បត្តិរបស់ខ្លួន ដោយពុំគិតពីកំហុស ឬភាពមានចេតនាឬគ្មានចេតនារបស់បុគ្គលនោះឡើយ។ ជាគោលការណ៍ កាលណាមានព្យសនកម្មកើតឡើងលើភាគីរងគ្រោះ ដោយមូលហេតុមកពីគ្រប់វត្ថុណាមួយដែលមានម្ចាស់ នោះកម្មសិទ្ធិករមិនអាចរួចផុតពីការទទួលខុសត្រូវនោះទេ មានន័យថា កម្មសិទ្ធិករត្រូវទទួលខុសត្រូវលើអំពើនៃវត្ថុគ្រប់ប្រភេទរបស់ខ្លួន បើសិនណាវាបានបង្កការខូចខាតដល់អ្នកដទៃ ហើយវាត្រូវបានសន្មតថាជាកំហុសរបស់កម្មសិទ្ធិករ។ មានព្យសនកម្មកើតឡើងទើបមានការទទួលខុសត្រូវ ប៉ុន្តែកាលបើជនរងគ្រោះ ពុំធ្វើការដាក់បន្ទុកដោយបង្ហាញភ័ស្តុតាងដើម្បីបញ្ជាក់ពីកំហុសទេ នោះក៏គ្មានការទទួលខុសត្រូវដែរ។ ចំណុចនៃការដាក់បន្ទុកដោយបង្ហាញភ័ស្តុតាង អាចមានដូចជាការលើកឡើងពីការចូលរួមនៃវត្ថុពិតប្រាកដ ទាក់ទងនិងទំហំនៃព្យសនកម្មដែលអាចមានការប៉ះពាល់ជាសម្ភារៈ និងមិនមែនជាសម្ភារៈជាដើម។ ដោយឡែក ចំពោះការរួចផុតពីការទទួលខុសត្រូវរបស់អ្នកកាន់កាប់វត្ថុ អាចកើតឡើងបានក្នុងករណីជនរងពុំអាចធ្វើការបង្ហាញពីភ័ស្តុងក្នុងការទំលាក់កំហុសលើអ្នកកាន់កាប់វត្ថុឬមានមូលហេតុខាងក្រៅចូលរួម។

មួយវិញសោត ការយល់ដឹងរបស់ប្រជាជនមួយចំនួនអំពីច្បាប់ សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួននៅមានមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ អាស្រ័យហេតុនេះកាលបើមានវិវាទដែលកើតពីអំពើនៃវត្ថុ ភាគីទាំង

សងខាងតែងតែទំលាក់បន្ទុកលើគ្នាទៅវិញទៅមក ឬមានការយល់ច្រឡំរវាងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។ បញ្ហានេះ បានបណ្តាលឱ្យមានភាពរញ៉េរញ៉ៃ និងស្មុគស្មាញខ្លាំងក្នុងការដោះស្រាយ ដោយអាចបង្កឱ្យមានជម្លោះកាន់តែខ្លាំងឡើង ខាតបង់ពេលវេលា និងថវិការផងដែរ។ យ៉ាងណាមិញ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី មានលក្ខណៈខុសពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ត្រង់ថាបើពុំមានការទាមទារពីជនរងគ្រោះ នោះចៅក្រមក៏មិនមានសិទ្ធិក្នុងការសម្រេចរឿងសំណងរដ្ឋប្បវេណីជូនជនរងគ្រោះបានទេ។ ហេតុនេះហើយ វាជាការចាំបាច់សម្រាប់ជនគ្រប់រូបត្រូវធ្វើការយល់ដឹងឱ្យបានច្បាស់ ដើម្បីចៀសវាងនូវការខាតបង់ថែមទៀត។

សរុបសេចក្តីមក ការទទួលខុសត្រូវលើអំពើរបស់វត្ថុ ដែលជាការទទួលខុសត្រូវលើអំពើអនីត្យានុកូលបានឆ្លុះបញ្ចាំងពីបញ្ហាទូទៅប្រចាំថ្ងៃដែលកំពុងជួបប្រទះក្នុងសង្គមបច្ចុប្បន្ន។ តាមរយៈការពន្យល់ និងបកស្រាយដោយផ្អែកលើគោលការណ៍មូលដ្ឋាននៃច្បាប់ បូករួមទាំងបានលើកយកឧទាហរណ៍ជាក់ស្តែងក្នុងសង្គមសម្រាប់ផ្តល់ពុទ្ធិបន្ថែម ព្រមទាំងធ្វើការក្រើនរំលឹកដល់ប្រជាជនទាំងអស់ឱ្យមានការប្រុងប្រយ័ត្នខ្ពស់លើការគ្រប់គ្រងវត្ថុរបស់ខ្លួនចៀសវាងមានភាពអន្តរាយកើតឡើង។

# អនុសាសន៍

ដោយឆ្លងកាត់តាមការស្រាវជ្រាវរបស់យើងខ្ញុំកន្លងមកឃើញថា ការទទួលខុសត្រូវអំពើនៃវត្ថុ គឺកើតមានឡើងជាច្រើន ដែលបង្កអោយមានការខូចខាតកើតមានទៅដល់បុគ្គលដែលជាជនរងគ្រោះមិនថាជាលក្ខណៈធំដុំក្តី ហើយនៅក្នុងករណីមួយចំនួនសំណងនៃព្យសនកម្មមិនមានលក្ខណៈស្របទៅតាមការកំណត់របស់ច្បាប់នោះទេ ដោយសារតែពេលខ្លះជនរងគ្រោះមិនទទួលបាននូវសំណងព្យសនកម្មទៅតាមទំហំនៃការខូចខាតរបស់ខ្លួន ឬពេលខ្លះទំហំនៃសំណងព្យសនកម្មមិនសមាមាត្រទៅនឹងទំហំនៃការខូចខាតរបស់ជនរងគ្រោះ។

ក៏ប៉ុន្តែ បញ្ហាទាក់ទងទៅនឹងព្យសនកម្មដែលកើតឡើងដោយវត្ថុទូទៅផ្សេងៗ ដោយហេតុថាទំហំនៃព្យសនកម្មរបស់វាមានការប៉ះពាល់ខ្លាំងទៅដល់ជនរងគ្រោះច្រើននាក់ដែលយើងមិនគួរមើលរំលង។ រាជរដ្ឋាភិបាល ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធគួរតែចាត់វិធានការទៅលើបញ្ហាមួយនេះឲ្យបានជាក់លាក់ ដើម្បីធានាទៅដល់សុខសុវត្ថិភាពរបស់ប្រជាជនជាផលវិបាកមួយ ដែលកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្នហើយក៏បានហុចនូវផលនិងដើម្បីបង្ការកុំឲ្យមាននូវហានិភ័យគ្រោះថ្នាក់ណាមួយកើតមានឡើង ដោយសារតែវត្ថុផ្សេងៗ។ មិនតែប៉ុណ្ណោះគួរតែបង្កើតឲ្យមាននូវបញ្ញត្តិច្បាប់ ឬវិធានការគ្រប់គ្រងឲ្យបានតឹងរ៉ឹងនិង មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងការទទួលខុសត្រូវទៅលើសំណងព្យសនកម្ម ដែលកើតមានឡើងដោយសារតែវត្ថុទូទៅដែលគ្រោះនេះដើម្បីឲ្យជនរងគ្រោះទទួលបាននូវសំណងនៃការខូចខាតពីជនដែលបង្កឡើងដោយសមរម្យ និងស្របទៅតាមការកំណត់របស់ច្បាប់។

ហើយលើសពីនេះទៅទៀត បុគ្គលគ្រប់រូបមិនថារូបវន្តបុគ្គល ឬនីតិបុគ្គលនោះទេក៏ត្រូវរួមចំណែកនៅក្នុងបញ្ហាមួយនេះដោយគួរតែមានការប្រុងប្រយ័ត្ន និងគោរពទៅតាមការកំណត់របស់ច្បាប់នៅក្នុងការទទួលខុសត្រូវដើម្បីជួយបង្ការ និងកាត់បន្ថយនូវការកើតឡើងនូវការខូចខាតណាមួយដែលពាក់ព័ន្ធទៅនឹងវត្ថុទូទៅផ្សេងៗទៅកាន់ជនរងគ្រោះ ព្រមទាំងជួយកាត់បន្ថយនូវបញ្ហាដែលកើតមានឡើងនៅក្នុងសង្គមបានមួយចំណែកផងដែរ។ ហេតុដូចនេះក្រៅពីរាជរដ្ឋាភិបាល យើងគ្រប់រូបក៏មានតួនាទីសំខាន់នៅក្នុងបញ្ហានេះដែរ ព្រោះដើម្បីកុំឲ្យមានជនរងគ្រោះណាមួយដែលទទួលរងនូវការខូចខាតតែបញ្ហាវត្ថុទូទៅផ្សេង។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រឹត្យច្បាប់, លេខ ៣៨ ក្រ.ច, ២៨ តុលា ១៩៨៨។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម, លេខ នស/រកម/០១១២/០០៥/៣០, ធ្នូ ២០១១។

ច្បាប់ស្តីពីការគ្រប់គ្រង់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ, លេខ នស/រកម/០៦០៥/០១៦, ១២ ឧសភា ២០០៥។

ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦/១៥, សីហា ២០០២។

អនុក្រឹត្យស្តីពីការគ្រប់គ្រង់គ្រឿងសម្អាង, លេខ១២២អនក្រ/បក, ០៨ តុលា ២០០៨។


## ឯកសារផ្សេងៗ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០០៣. *សៀវភៅស្តីពីវិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ក្នុងការប្រើប្រាស់ និងការទុកដាក់ថ្នាំកសិកម្ម*. ភ្នំពេញ។

ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០, ភាគ៣ គន្លឹទី៥។

ញឹក វុទ្ធី. គ្មានកាលបរិច្ឆេទ. *នីតិកាតព្វកិច្ចភាគ២*. ភ្នំពេញ។

សួស ចំរើន. ២០០៣. គ្រប់គ្រងសំណង់។

ហាប់ ផល្លី, កែសម្រួល, នីតិរដ្ឋប្បវេណី១ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១៥), ២៨។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ក្រមរដ្ឋប្បវេណី

## ជំពូកទី ១៦

## អំពើអនីត្យានុកូល

# ព្រះរាជក្រម

នស/រកម/១២០៧/០៧០

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ១៦
# អំពើអនីត្យានុកូល

**មាត្រា ៧៤២.–** និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

**មាត្រា ៧៤៣.-** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

**មាត្រា ៧៤៤.-** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

**មាត្រា ៧៤៥.-** អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្តាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

**មាត្រា ៧៤៦.–** ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

**មាត្រា ៧៤៧.–** ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបាន ដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

**មាត្រា ៧៤៨.–** អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

**មាត្រា ៧៤៩.–** អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

**មាត្រា ៧៥០.–** ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

**មាត្រា ៧៥១.–** ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាល ឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

**មាត្រា ៧៥២.–** ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

**មាត្រា ៧៥៣.–** ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

**មាត្រា ៧៥៤.—** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.—** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.—** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

យល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

**មាត្រា ៧៥៧.–** គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

**មាត្រា ៧៥៨.–** ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើ

អនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

**មាត្រា ៧៥៩.–** ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

**មាត្រា ៧៦០.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្ដល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលដែលទទួលជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅ

ជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅ



ក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

**មាត្រា ៧៦១.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

**មាត្រា ៧៦២.–** ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

**មាត្រា ៧៦៣.–** ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៤.–** ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាត តុលាការ

អាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៥.-** អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។

# ឧបសម្ព័ន្ធទី២

## ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា
- ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់រដ្ឋសភាលើកទី ២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងអាវុធ

# គ្រឿងផ្ទុះ និង គ្រាប់រំសេវ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

វិសាលភាពនៃច្បាប់នេះគ្របដណ្តប់លើការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ៣.-**

វាក្យសព្ទ ដូចចែងក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម :

ក-អាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតម្លើង ដែលអាច ប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

ខ-គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈដែលគេផលិត ឬ កែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិ ។

គ-អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដ៏ទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុ ដែលគេផលិត ឬ កែច្នៃតម្លើង អាចបង្កគ្រោះថ្នាក់ដល់ សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និង បរិស្ថាន ។

ឃ-កងកម្លាំងឯកសណ្ឋាន សំដៅដល់កងកម្លាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ។

ង-មន្ត្រី សំដៅដល់អ្នករាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំងឡាយ និង មន្ត្រីតុលាការ មន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ ។

ច-ជនស៊ីវិលសំដៅដល់ជនទាំងឡាយ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ឃ និង ង ។

## ជំពូកទី ២

## ការគ្រប់គ្រង ការផ្គត់ផ្គង់

## ការដឹកជញ្ជូន អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ៤.-**

ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

ត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ក . ខ . គ នៃមាត្រា ៣ ក្នុងច្បាប់នេះ :

- កាំភ្លើង និង គ្រាប់បាញ់កំណត់សញ្ញា

- កាំភ្លើង និង គ្រាប់បាញ់សម្រាប់សកម្មភាពកីឡា

- កាំភ្លើងដែលបាញ់ មិនមានបញ្ចូនក្បាលគ្រាប់ ឬ គ្រាប់ប្រាយ ។ កាំភ្លើងបាញ់បញ្ចុះកាំជ្រួចលំអ ឬ កាំភ្លើងផ្ទុះស្នូរគ្មានក្បាលគ្រាប់សម្រាប់សំដែងសិល្បៈ ។

- គ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ សម្រាប់ផ្ទុះលំអ ។

ល័ក្ខខ័ណ្ឌ និង នីតិវិធី សម្រាប់អនុវត្តន៍មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

ត្រូវបានអនុញ្ញាតឱ្យតែក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិមានក្លឹប និង ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ។

**មាត្រា ៧.-**

ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើ ពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លង

កាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទដល់កងកម្លាំងឯកសណ្ឋាន និង មន្ត្រី ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨.-**

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់ ឬ ប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាលអាចផ្តល់ការលើកលែងចំពោះអង្គរក្សបរទេសមាន : អង្គរក្សរបស់ព្រះមហាក្សត្រ ឬ ព្រះមហាក្សត្រីយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយក- រដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ ដែលយាង ឬ អញ្ជើញមកធ្វើទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៩.-**

ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ១០.-**

ក្រសួងការពារជាតិ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ របស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

**មាត្រា ១១.-**

ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទដល់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទដល់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ត្រូវមានបញ្ជាក់អំពីប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ នឹងល័ក្ខខ័ណ្ឌដែលត្រូវគោរព។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់អង្គភាពត្រូវបានបញ្ជាក់បន្ថែម អំពីកាតព្វកិច្ចតម្រូវឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវមករក្សាទុកក្នុងឃ្លាំងវិញ ។

នីតិវិធី និង ល័ក្ខខ័ណ្ឌ ស្តីពីការសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

ក្រសួងការពារជាតិ ទទួលខុសត្រូវលើសុវត្ថិភាព និងសន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជន ស៊ីវិល ។

អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងអស់ត្រូវចុះក្នុងបញ្ជី ហើយអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។

**មាត្រា ១៣.-**

ដើម្បីធានា សុវត្ថិភាពសាធារណៈ និង ដើម្បីបង្ការ ទប់ស្កាត់ គ្រោះមហន្តរាយ ដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាច បញ្ជាឱ្យជន្លៀស សាធារណជន ចេញជាបណ្តោះអាសន្ន ពីលំនៅដ្ឋាន ឬ តំបន់ ក្នុងករណីដឹងថាមានគ្រោះថ្នាក់កើតឡើង ។

បែបបទនៃការអនុវត្តន៏មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៤.-**

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់ក្រសួងការពារជាតិ បើក្នុងគោលដៅការពារជាតិ . ឬ របស់ក្រសួងមហាផ្ទៃ បើក្នុងគោលដៅការពារ សន្តិសុខផ្ទៃក្នុងប្រទេស ។

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា មកពីក្រៅប្រទេសអាចធ្វើទៅបាន លុះត្រាតែបានការយល់ព្រមពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

**មាត្រា ១៥.-**

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលបាននឹងកំពុងកាន់កាប់ ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយពេលដឹងថាបាត់ដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឬ ប៉ុស្តិ៍កងរាជអាវុធហត្ថ នៅទីកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សី សមត្ថកិច្ចនៅកន្លែងកើតហេតុត្រូវចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលស្តុកទុកក្នុងឃ្លាំង ឬ ក្នុងអង្គភាពនាយផ្នាំ ឬ អ្នកទទួលខុសត្រូវថែរក្សាត្រូវរាយការណ៍ដល់មេបញ្ជាការ ឬ ប្រធានអង្គភាព មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយដឹងថាបាត់ ។ មេបញ្ជាការ ឬ ប្រធានអង្គភាព ត្រូវចាត់វិធានការត្រួតពិនិត្យស្រាវជ្រាវជាបន្ទាន់ ។

របាយការណ៍ស្តីពីការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិត ទាក់ទង នឹងប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និង កាលៈទេសៈនៃការបាត់ ។

**មាត្រា ១៦.-**

ការបំផ្លាញអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ឬការលុបចេញពីបញ្ជី ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទនោះ ស្ថិតក្នុងសមត្ថកិច្ច របស់ក្រសួងមហាផ្ទៃ ឬ មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនោះស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ។

**មាត្រា ១៧.-**

ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតគណៈកម្មការជាតិ ដើម្បីត្រួតពិនិត្យដឹកនាំឬ កែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការនាំចូល ការនាំចេញ ការជួសជុល
## ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ១៨.-**

ការនាំចូល ការនាំចេញ ការជួសជុល ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតឱ្យមានរោងជាងជួសជុលនិងទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

ការនាំចូល ការនាំចេញ ការផលិតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ត្រូវស្របតាមគោលការណ៍ និងវិធានទាំងឡាយរបស់អន្តរជាតិដែលពាក់ព័ន្ធ ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ខែ ដល់ ១(មួយ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០,០០០ (ម្ភៃម៉ឺន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២០.-**

ជនណាដែលបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួលកែច្នៃតម្លើង ជួសជុល នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ២(ពីរ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២១.-**

ជនណាដែលធ្វេសប្រហែស ឱ្យជនដទៃ យកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ដែលខ្លួនកាន់កាប់ទៅប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ២ (ពីរ)ឆ្នាំនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៧០០.០០០ (ចិតសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២២.-**

មន្ត្រីដែលក្រសួងមានសមត្ថកិច្ច ប្រគល់ឱ្យចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ តែការផ្តល់ប័ណ្ណសម្គាល់សិទ្ធិ ប្រើប្រាស់នោះ ពុំបានត្រឹមត្រូវខុសសមត្ថកិច្ចរបស់ខ្លួនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលពុំមែនជាសមត្ថកិច្ច ហើយបានចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្រោមរូបភាពណាមួយ ឬ ដោយមូលហេតុណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ៨(ប្រាំបី)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

ជនណាដែលធ្វើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយក្លែងបន្លំ ឬ បានប្រើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយដឹងថាក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ ។

**មាត្រា ២៣.-**

ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬ ស្តុកនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

**មាត្រា ២៤.-**

ជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៨ និងមាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៥.-**

ក្នុងរយៈពេល ៣ (បី)ខែ យ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ជនណាដែលបានកាន់កាប់ អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតត្រូវយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទទាំងនោះ មកប្រគល់ឱ្យអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

នរស. ០៥០៦.២៦៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

- បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ២២៤ ច.ល

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា និងព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវឌ្ឍ**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**សុខ តាន់**